ទស្សនាវដ្តី

ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី៧៦ លេខ ២៥៤ ខែកក្កដា ឆ្នាំ ២០២២

ព្រះមហាក្សត្រកម្ពុជាអំពាវនាវដល់ជនរួមជាតិ
បន្តទប់ស្កាត់ការកាប់បំផ្លាញ
ព្រៃឈើ និងបញ្ឈប់ការប្រមាញ់សត្វព្រៃ

៦

សន្និបាត
គណៈកម្មាធិការកណ្តាលវិសាមញ្ញ
របស់គណបក្សប្រជាជន...

១០

សម្តេចពេជោ ហ៊ុន សែន ៖
បោះឆ្នោតឱ្យគណបក្សប្រជាជន
ជាការបោះឆ្នោតឱ្យខ្លួនឯង ដើម្បី ....

១២

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ៖
ការពារដាច់ខាតសន្តិភាព ស្ថិរភាពនយោបាយ
និងជំរុញការអភិវឌ្ឍគោលនយោបាយ.....

១៥

ឯកឧត្តម **ហ៊ុន ម៉ាណែត ៖**
បន្តរួបរួមគ្នាជាកម្លាំងមហាសាមគ្គី
ជាតិខ្មែរ ដើម្បីបន្តថែរក្សាការពារជាតិខ្មែរ...

១៦

និពន្ធនាយក :
លោក តាក ស៊ុនអ៊ី
គណៈកម្មការនិពន្ធ
១. លោក ខៀវ ណាវី
២. លោក អ៊ឹម សុន្ទរៈ
៣. លោក វង្ស សាវុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
៦. លោក ងួន កុលបុត្រ
៧. លោក មាន សេរីរិត
លេខានិពន្ធ
១. លោក ស្វាយ ភីរុណ
២. លោក ម៉ក់ ឈិន
អ្នកបកប្រែភាសា
១. លោកស្រី ម៉ែន នារីសោភ័គ
អ្នកថតរូប
១. លោក សុផាត វីរៈមុនី
វិចិត្រករ
១. លោក ធា សាវុធ
អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥
Address :
No 203 Preah
Norodom Bld.
Phnom Penh Cambodia
Tel : 023 219 065

មាតិកា
Contents

ក្របមុខ : សន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញ
របស់គណបក្សប្រជាជនកម្ពុជា

- *វិចារណកថា : អនុវត្តឲ្យបានជោគជ័យស្មារតីសន្និបាតគណៈកម្មាធិការកណ្តាល ០២*
- *Editorial : Successfully Implement the Spirit of the Central Committee ០២*
- *អត្ថបទនយោបាយ: វិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ ដើម្បីបម្រើឧត្តមប្រយោជន៍ ០៥*
- *សេចក្តីជូនដំណឹង ស្តីពីលទ្ធផលនៃសន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញ របស់ ០៧*
- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១៧*
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ២១*
- *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ២៣*
- *វិស័យថាមពលអគ្គិសនីកម្ពុជា ជាកត្តាចម្បង និងចាំបាច់មួយសម្រាប់គាំទ្រដល់ការអភិវឌ្ឍ ២៤*
- *វប្បធម៌: ប្រវត្តិខេត្តកំពង់ចាម ២៦*
- *ចំណេះដឹងទូទៅ: ប្រទេសជាច្រើននឹងប្រឈមមុខវិបត្តិស្បៀងអាហារដោយគ្មានផលិតផល ២៧*
- *វិទ្យាសាស្ត្រ និងសុខភាព: ពេលវេលាល្អ និងរបៀបទទួលទានទឹកដោះគោឱ្យបានត្រឹមត្រូវ ២៨*
- *ទឹកដីមាតុភូមិ: ស្រុកឆែប ផ្លាស់ប្តូរពីភាពស្ងាត់ជ្រងំ មកជាតំបន់មានការអភិវឌ្ឍ និងជា ២៩*
- *កំណាព្យ: វស្សាឆ្នាំថ្មី ..... សំណើច ៣២*

សូមប្រសិទ្ធពរជ័យមហាប្រសើរដ៏ឧត្តម

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណបក្សប្រជាជនកម្ពុជា ជានិច្ចកាលជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៧០ ឈានចូល ៧១ ឥស្សរជនរបស់សម្តេច

យើងខ្ញុំសូមលំអោនកាយគោរពដោយក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុត ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជាដែលបានលះបង់អស់កម្លាំងកាយកម្លាំងចិត្ត និងបញ្ញាញាណ ក្នុងការដឹកនាំប្រទេសឆ្លងកាត់ឧបសគ្គរាប់មឺនសែនជំពូក ប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃ និងភាពអង់អាចក្លាហាន តាំងពីដំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍រហូតមកដល់បច្ចុប្បន្ននេះ សម្រេចបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រដ៏ថ្លៃថ្លាវិសេសវិសាលបំផុត ដែលបានធ្វើឲ្យប្រទេសជាតិមានសន្តិភាពពេញលេញ ឯកភាពជាតិ ឯកភាពទឹកដី និងមានការអភិវឌ្ឍលើគ្រប់វិស័យប្រជាជនមានសិទ្ធិសេរីភាពបរិបូរនិងរស់នៅយ៉ាងសុខដុមរមនាការពារយ៉ាងរឹងមាំនូវឯករាជ្យអធិបតេយ្យ និងបូរណភាព ទឹកដី ហើយកំពុងបន្តឈានទៅមុខយ៉ាងស្វាហាប់ លើមាគ៌ាសន្តិភាព និងប្រជាធិបតេយ្យ ឆ្ពោះទៅសម្រេចគោលដៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។*

សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ព្រមទាំងតេជៈបារមីនៃវិញ្ញាណក្ខ័ន្ធរបស់បុព្វវីរបុរសខ្មែរគ្រប់ៗជំនាន់ សូមជួយប្រោះព្រំ គាំពារ ថែរក្សា ***សម្តេចអគ្គមហាសេនាបតីតេជោ*** *សម្រេចបានជោគជ័យ ធំៗថ្មីៗទៀត ក្នុងការដឹកនាំប្រទេសកម្ពុជា និងសូមគោរពជូនពរសម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី បានប្រកបនូវពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជារៀងដរាប ។*

គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត

ទស្សនាវដ្តីប្រជាជន

វិចារណកថា EDITORIAL

អនុវត្តឲ្យបានជោគជ័យស្មារតីសន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញរបស់គណបក្សប្រជាជនកម្ពុជា

Successfully Implement the Spirit of the Central Committee Extraordinary Conference of the Cambodian People's Party

សន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញរបស់គណបក្សប្រជាជនកម្ពុជា បានប្រព្រឹត្តទៅប្រកបដោយជោគជ័យពីថ្ងៃទី១៦-១៧ ខែកក្កដា ឆ្នាំ ២០២២ ដែលនេះជាព្រឹត្តិការណ៍នយោបាយជាប្រវត្តិសាស្ត្របន្ទាប់ពីគណបក្សប្រជាជនកម្ពុជា បានទទួលជ័យជម្នះដ៏ធំធេងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ និងជោគជ័យនៃការប្រារព្ធមិទ្ទិញដ៏ឧឡារឹក រំលឹកខួបទី ៧២ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨ មិថុនា ១៩៥១-២៨ មិថុនា ២០២២) ។

*អង្គសន្និបាតបានប្រមូលផ្តុំបញ្ញាញាណ ធ្វើការពិភាក្សាយ៉ាងម៉ឺងម៉ាត់ក្នុងស្មារតីឯកភាព ប្រជាធិបតេយ្យ និងការទទួលខុសត្រូវខ្ពស់ចំពោះឧត្តមប្រយោជន៍ជាតិទៅលើបញ្ហាសំខាន់ៗ មួយចំនួន រួមមាន៖ ជោគជ័យនៃដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ កាលពីថ្ងៃទី ៥ មិថុនា ឆ្នាំ ២០២២ ដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាសអព្យាក្រឹត សន្តិសុខ របៀបរៀបរយ គ្មានអំពើហឹង្សា និងការគំរាមកំហែង ។ អង្គសន្និបាតក៏បានពិភាក្សា និងកំណត់អំពីកត្តាធំៗនៃជ័យជម្នះរបស់គណបក្សដែលត្រូវយកចិត្តទុកដាក់ពង្រឹងពង្រីកបន្តទៀត ព្រមទាំងលើកឡើងអំពីចំណុចខ្វះខាត ដែលត្រូវខិតខំបន្តដោះស្រាយឲ្យបានល្អត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រឹងជំនឿទុកចិត្តរបស់ប្រជាជនចំពោះការដឹកនាំរបស់គណបក្ស ។ ដោយបានបង្ហាញពីការគាំទ្រពេញទំហឹង ចំពោះការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងរក្សាស្ថិរភាពជីវភាពរស់នៅរបស់ប្រជាជននាយៈពេលកន្លងមក ជាពិសេសក្នុងដំណាក់កាលដ៏លំបាកបំផុតនៃវិបត្តិសកលជំងឺកូវីដ-១៩ ព្រមទាំងអបអរសាទរសមិទ្ធផលធំៗដែលរាជរដ្ឋាភិបាលសម្រេចបាន អង្គសន្និបាតបានបញ្ជាក់ជាឱឡារិក នូវការគាំទ្រដល់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាបេក្ខភាពនាយករដ្ឋមន្ត្រីសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា និងគាំទ្រឯកឧត្តម **ហ៊ុន ម៉ាណែត** ជាបេក្ខភាពនាយករដ្ឋមន្ត្រីសម្រាប់ពេលអនាគត ។ អង្គសន្និបាតបានគាំទ្រទាំងស្រុងសំណើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សំដៅបម្រើឧត្តមប្រយោជន៍របស់ជាតិ គឺការធានាឲ្យស្ថាប័នរបស់ជាតិ ជាពិសេសអំណាចនីតិប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋមានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាលៈទេសៈ*

The Extraordinary Conference of the Central Committee of the Cambodian People's Party (CPP) successfully held from 16-17 July 2022. It is the party's historic political event after the CPP won a landslide victory in the 5th term Commune/Sangkat Council election and the success of the solemn celebration of the 72nd anniversary of the founding of the Cambodian People's Party (June 28, 1951 - June 28, 2022).

The conference gathered intelligence and focused on in-depth discussions in the spirit of unity, democracy and high responsibility for the national interest on a number of key issues, including success of the 5th term Commune/Sangkat Council Election process on 5 June 2022, held in a free, fair and just, in a neutral environment, security, orderly manner, non-violence and without intimidation. The conference also discussed and identified major factors of the party's victory, which need to be further strengthened and highlighted, as well as the shortcomings that need to be addressed in a timely and effective manner to strengthen people's trust in the party leadership.

Expressing full support for the Royal Government's efforts to develop the economy and stabilize the living standards of the people in the past, especially in the most difficult stages of the global crisis of Covid-19, and to celebrate major achievements of the Royal Government, the conference solemnly expressed their support for Samdech Akka Moha Sena Padei Techo Hun Sen as the Prime Ministerial candidate for the 7th legislature of the National Assembly and His Excellency Hun Manet as the future Prime Ministerial candidate. The conference fully supported the proposed 10th amendment of the Constitution of the Kingdom of Cambodia aiming to serve the national interest, which is to ensure that national institutions, especially the executive branch, have the primary mission of leading the general functioning of the state, smooth and sustainable functioning in all circumstances, and ensure the protection and maintenance of peace, social security, public order and political stability of the nation in all

និងការធានាការពារ និងថែរក្សាឲ្យបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិ នៅគ្រប់កាលៈទេសៈ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យ និងសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជា ។

អង្គសន្និបាតបានវាយតម្លៃខ្ពស់ចំពោះអត្ថន័យនៃជ័យជម្នះដ៏ធំធេងរបស់គណបក្សក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ៥ ដោយចាត់ទុកថា នេះជាសំឡេងគាំទ្រប្រកបដោយគុណភាព ដែលចេញពីវិចារណញ្ញាណ និងឆន្ទៈរបស់ប្រជាជន ដែលមើលឃើញយ៉ាងច្បាស់នូវស្នាដៃ ទស្សនវិស័យ និងសមត្ថភាពនៃការដឹកនាំរបស់គណបក្ស ហើយសង្ឃឹមយ៉ាងមុតមាំថា គណបក្សប្រជាជនកម្ពុជា នឹងបន្តទទួលបានជ័យជម្នះធំធេងថែមទៀត នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ ឆ្នាំ ២០២៣ ខាងមុខ ។

ឆ្នាំ២០២៣ គឺជាឆ្នាំទី ៥ និងជាឆ្នាំចុងក្រោយនៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា ជាឆ្នាំដែលពោរពេញដោយវិញ្ញាសារតានតឹង ជាច្រើនដែលត្រូវដោះ-ស្រាយ អាស្រ័យដោយផលវិបាកមួយផ្នែកដោយសារកត្តាខាងក្នុង និងមួយផ្នែកធំដោយសារកត្តាខាងក្រៅ បណ្តាលមកពីការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ សង្គ្រាមរវាង រុស្ស៊ី និងអ៊ុយក្រែន និងភាពស្មុគស្មាញ ដែលបណ្តាលមកពីបញ្ហាអន្តរជាតិមួយចំនួនទៀត ។ អ្វីដែលយើងមើលឃើញច្បាស់អំពីផលប៉ះពាល់ដែលកើតមានរួចជាស្រេច បណ្តាលមកពីវិបត្តិសកលទៅលើបណ្តាប្រទេសមួយចំនួន គឺ វិបត្តិស្បៀងអាហារ និងវិបត្តិថាមពល ដែលធ្វើឲ្យប្រទេសខ្លះជួបនឹងបញ្ហាសេដ្ឋកិច្ច ជាពិសេសគឺកំណើនអតិផរណាខ្ពស់ ធ្វើឲ្យប៉ះពាល់ខ្លាំងទៅដល់ជីវភាពសេដ្ឋកិច្ច សង្គម ។

លើមូលដ្ឋានការវាយតម្លៃអំពីសភាពការណ៍ទូទៅបច្ចុប្បន្ន និងការប៉ាន់ស្មានអំពីលទ្ធភាពនៃការវិវត្តសភាពការណ៍ខាងមុខ ព្រមទាំងសំណូមពរការងារឆ្ពោះទៅការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រនីតិកាលទី៧ អង្គសន្និតបាតបានពិភាក្សា និងអនុម័តទិសដៅការងារសំខាន់ៗសម្រាប់ឆ្នាំ២០២២ និងឆ្នាំ ២០២៣ គឺ ខិតខំការពារឲ្យបានដាច់ខាតសន្តិភាពស្ថិរភាពនយោបាយសន្តិសុខសណ្តាប់ធ្នាប់សង្គម ទប់ស្កាត់ការប៉ុនប៉ង បង្កចលាចលពីសំណាក់ពួកប្រឆាំងជ្រុលនិយម និងមជ្ឈដ្ឋានអតិ សំដៅធានាដំណើរការអភិវឌ្ឍឲ្យប្រព្រឹត្តទៅ ជានិរន្តរ និងធានាឲ្យការរស់នៅរបស់ប្រជាជនប្រកបដោយសុខក្សេមក្សាន្ត ។ បន្តជំរុញខ្លាំងក្លា យុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាជនដោយឥតគិតថ្លៃ និងជំរុញអនុវត្តបណ្តាវិធានការដទៃទៀត គួបផ្សំជាមួយវិធានការសុខាភិបាលទប់ស្កាត់ឲ្យបានការឆ្លងរីករាលដាលជាថ្មីនៃជំងឺកូវីដ-១៩បង្កើតឲ្យបានភាពស៊ាំសហគមន៍ ហើយរួមគ្នាអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីស្តារ និងជំរុញ កំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩ តាម គន្លងប្រក្រតីភាពថ្មី ឆ្នាំ ២០២១-២០២៣ ។

circumstances as a foundation for the development of the nation in all areas and peaceful life of the people of Cambodia.

The conference highly appreciated the meaning of the party's great victory in the election of the 5th mandate Commune/Sangkat councilors, considering that this is a quality vote of support that comes from the intellect and will of the people who see clearly the works, the vision, and the ability of the party to lead, while strongly hope that the Cambodian People's Party will continue to win even greater in the upcoming 7th National Assembly election in 2023.

The year 2023 is the fifth and final year of the implementation of the Royal Government's political program for the sixth legislature of the National Assembly, a year full of many tense issues to address, due in one part to internal factors and in a larger part to external factors caused by the outbreak of Covid-19, the war between Russia and Ukraine, and the complications caused by some international issues. We see clearly the effects of the global crisis on some countries such as the food and the energy crisis, which is causing some countries to face economic problems, especially high inflation with harsh impacts on socio-economic life.

On the basis of an assessment of the current general situation and an estimate of the possibility of future developments, as well as work proposals towards the 7th legislative election, the conference discussed and approved the main work directions for 2022 and 2023 to strive for the absolute protection of peace, political stability, security, social order, to prevent attempts to provoke unrest by extremist opposition and the ill-willed circle aimed at ensuring the sustainable development process and guaranteeing the well-being of the people. The conference continues to intensify the free vaccination campaign against Covid-19 and promote the implementation of other measures combined with health measures to prevent the re-emergence of Covid-19 and build community immunity, while together, implementing the strategic framework of the program to restore and promote Cambodia's economic growth in living with Covid-19 in the new normal way for 2021-2023.

The conference decided to continue to push for in-depth reform in all sites with a strong will and in harmony with the "reflecting in mirror, taking a shower, and taking treatment and surgery" approach to continue to improve governance, to ensure the provision of

បន្តជំរុញកំណែទម្រង់ស៊ីជម្រៅនៅគ្រប់ការដ្ឋានដោយឆន្ទៈមុតស្រួច និងស្រុះដៃគ្នា តាមអភិក្រម "ឆ្ពុះកញ្ចក់ ដូតទឹក ព្យាបាល និងវះកាត់" ដើម្បីបន្តលើកកម្ពស់អភិបាលកិច្ច ធានាការផ្តល់សេវាសាធារណៈប្រកបដោយតម្លាភាព គណនេយ្យភាព និងឆាប់រហ័សជូនប្រជាពលរដ្ឋ ពង្រឹង យុត្តិធម៌ និងសមធម៌សង្គម ។ បន្តជំរុញការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ឲ្យកាន់តែល្អប្រសើរ ។ ថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ខិតខំទប់ស្កាត់អតិផរណា រក្សាអំណាចទិញរបស់ប្រាក់រៀលក្នុងស្ថានភាពដែលត្រូវរងផលប៉ះពាល់ពីការកើនឡើងជាសកលនៃតម្លៃទំនិញគ្រប់ប្រភេទ ។ ខិតខំដោះស្រាយតម្រូវការរបស់ប្រជាជន ជំរុញការអភិវឌ្ឍមូលដ្ឋាន ជំរុញការផលិតស្បៀង និងការនាំចេញអង្ករឲ្យបានច្រើន ។ ខិតខំដោះស្រាយជម្លោះដីធ្លីក្រៅប្រព័ន្ធឲ្យបានល្អ និងឆាប់រហ័ស ។ គាំទ្រ **"គម្រោងសម្តេចតេជោ សម្រាប់សកម្មភាពមីន"** ក្រោមមូលបទ **"ផ្តល់ដីសុវត្ថិភាព បង្កើត ស្នាមញញឹម"** ។ បន្តអនុវត្តគោលនយោបាយគាំពារសង្គម ជាពិសេស ជួយគាំពារជនក្រីក្រ ជនរងគ្រោះដោយសារជំងឺកូវីដ-១៩ និងអ្នក រងផលប៉ះពាល់ខ្លាំងពីការឡើងថ្លៃទំនិញ ។ ដំឡើងប្រាក់បៀវត្ស របស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កែសម្រួលប្រាក់សោធន-និវត្តន៍ និងជំរុញដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត ។ ជំរុញអនុវត្តគោលនយោបាយអភិវឌ្ឍឃុំ សង្កាត់ ឆ្នាំ២០២២-២០២៧ ដើម្បីឲ្យឃុំ សង្កាត់នីមួយៗទទួលសមិទ្ធផលថ្មីៗទៀត ។ ពង្រឹង រដ្ឋបាលមូលដ្ឋានអនុវត្តឲ្យបានល្អតួនាទីភារកិច្ច និងរបៀបរបបធ្វើការរបស់ខ្លួន ។ ជាមួយគ្នានេះត្រូវបង្កលក្ខណៈសម្បត្តិឲ្យបានល្អ ដើម្បីឈានទៅដណ្តើមជ័យជម្នះដ៏ត្រចះត្រចង់ជាថ្មីទៀត ក្នុងការបោះឆ្នោតសកលថ្នាក់ជាតិនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ។

ដើម្បីអនុវត្តឲ្យបានជោគជ័យស្មារតីនៃសន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញរបស់គណបក្សប្រជាជនកម្ពុជា គណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក មន្ត្រីគណបក្សទាំងអស់ ត្រូវខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ឲ្យបានល្អ ដោយពង្រឹងឲ្យបានឆ្លងសាមគ្គី ឯកភាពផ្ទៃក្នុងរឹងមាំ ពង្រឹងអង្គការមូលដ្ឋានគណបក្សថែទាំសមាជិកគណបក្ស ពង្រឹងការងារដឹកនាំអង្គការមហាជនរបស់គណបក្ស គ្រប់គ្រងសមាជិកគណបក្ស អនុវត្តឲ្យបានជោគជ័យការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្ររបស់គណបក្ស គឺ "ខិតខំរក្សាប្រៀបឈ្នះ និងបន្តពង្រីកប្រៀបឈ្នះក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៧ "។

ឆ្នាំ ២០២៣ គឺជាឆ្នាំនៃជ័យជម្នះធំៗថ្មីទៀតជាប្រវត្តិសាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា ៕

ទស្សនាវដ្តីប្រជាជន

transparent, accountable and expeditious public services to the people, and to strengthen social justice and equity. It determined to continue to promote better implementation of the policy of safe villages, communes and Sangkats. The conference resolved to maintain macroeconomic stability, strive to curb inflation, maintain the purchasing power of the Riel in a situation affected by the global rise in prices of all commodities. Strive to meet the needs of the people, promote local development, boost food production and export more rice. Strive to resolve land disputes out of court system well and quickly. Support the "Samdech Techo Project for Mine Action" under the theme "providing safe land, creating a smile." Th conference determined to continue to implement social protection policies, especially to help the poor, victims of Covid-19 and those most affected by rising commodity prices. Efforts will be made to increase the salaries of civil servants, the armed forces, to adjust pensions and push for an increase in the minimum wage of workers, and to promote the implementation of Commune/Sangkat Development Policy 2022-2027 so that each Commune/Sangkat can score new achievements, while strengthening local administrations, implementing well their roles, responsibilities and working procedures. At the same time, it is necessary to create good conditions to reach the glorious victory again in the national general election on July 23, 2023.

In order to successfully implement the spirit of the Extraordinary Central Committee Conference of the Cambodian People's Party, parties committee at all levels and party officials must strive to fulfill their roles and responsibilities well by strengthening solidarity, strong internal unity, and local organizations, while taking cares for the members of the party, strengthening the leadership of the mass organization of the party, managing the party members, and successfully implementing the party's strategic commitment to "strive to maintain the winning advantage and continue to expand the victory in the 7th legislative election."

2023 is the year of another major victory in the history of the Cambodian People's Party.

THE PRACHEACHUN MAGAZINE

សម្តេចតេជោ ហ៊ុន សែន ៖ ត្រូវបន្តជំរុញការកែទម្រង់ស៊ីជម្រៅនៅគ្រប់ការដ្ឋាន ដោយឆន្ទៈមុចស្រួច និង ស្រុះដៃគ្នា តាមអភិក្រម "ឆ្ពុះកញ្ចក់ ដូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"

វិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញ ដើម្បីបម្រើឧត្តមប្រយោជន៍របស់ជាតិ

សន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញនៃគណបក្សប្រជាជន ពីថ្ងៃទី១៦-១៧ ខែកក្កដា ឆ្នាំ២០២២ បានអនុម័តគាំទ្រទាំងស្រុងសំណើវិសោធនកម្មលើកទី១០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រាចំនួន ៨ នៃរដ្ឋធម្មនុញ្ញ រួមមានមាត្រា១៩ថ្មី (មួយ) មាត្រា ៨៩ មាត្រា ៩៨ថ្មី មាត្រា ១២២ថ្មី មាត្រា១១៩ថ្មី (មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញ មាត្រា ៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញ ត្រូវបានគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័ត ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២។ កាលពីថ្ងៃទី១៣ ខែកក្កដា ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំដើម្បីពិនិត្យទៅលើសេចក្តីព្រាងច្បាប់នេះ ដោយបានធ្វើការពិនិត្យពិច័យយ៉ាងល្អិតល្អន់ និងម៉ត់ចត់ ដោយបានសម្រេចជាឯកច្ឆ័ន្ទ ទូលថ្វាយមតិចំពោះ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ថា **សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្ម មាត្រាទាំង៨នេះ អាចធ្វើទៅបាន ហើយពុំមានអ្វីប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញឡើយ ព្រមទាំងបានធ្វើឡើងនៅពេលដែលប្រទេសជាតិមិនស្ថិតក្នុងភាពអាសន្ន**។

វិសោធនកម្មរដ្ឋធម្មនុញ្ញនេះ ទាក់ទងទៅនឹងមាត្រាមួយចំនួន អំពីការតែងតាំងនាយករដ្ឋមន្ត្រី និងដំណើរការក្នុងរដ្ឋសភា ដោយមានគោលបំណងសំខាន់គឺ **ទី១- ជានាឲ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេស អំណាចនីតិប្រតិបត្តិ ដែលមានបេសកកម្មចម្បង ក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ មានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាព និងទី២- ជានាការពារ និងថែរក្សាឲ្យបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ ស្ថិរភាពនយោបាយប្រទេសជាតិ នៅគ្រប់កាលៈទេសៈ ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ និងភាពសុខសាន្តរបស់ប្រជាជន**។ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី ១០ នេះ ក៏ដើម្បីបំពេញចន្លោះខ្វះខាតរដ្ឋធម្មនុញ្ញ ហើយអ្វីដែលសំខាន់ គឺបំពេញបន្ថែមចំពោះរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ក្នុងគោលបំណងការពារឧត្តមប្រយោជន៍របស់ជាតិ។

មជ្ឈដ្ឋានអគតិ និងក្រុមប្រឆាំងផ្តាំមុខ បានប្រតិកម្មទាំងទទឹងទិស និងប្រកបដោយភាពងងឹតងងុលបំផុត និងបានធ្វើការវាយប្រហារយ៉ាងកំរោលទៅលើការស្នើឲ្យមានសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ។ ប៉ុន្តែប្រជាជនកម្ពុជាបានសម្តែងការគាំទ្រយ៉ាងខ្លាំង ពីព្រោះថា ខ្លឹមសារទាំងឡាយនៅក្នុងសេចក្តីព្រាងច្បាប់ធម្មនុញ្ញនេះ គឺដើម្បីជានានូវនិរន្តរភាពការងារនៃស្ថាប័នរដ្ឋ ទាំងស្ថាប័ននីតិបញ្ញត្តិ ទាំងស្ថាប័ននីតិប្រតិបត្តិ មិនឲ្យមានការជាប់គាំង ជានាឲ្យសង្គមជាតិមានស្ថិរភាព ប្រជាជនបានរស់នៅដោយសុខសប្បាយ ប្រកបអាជីវកម្មជាប្រក្រតី។ សេចក្តីព្រាងច្បាប់ធម្មនុញ្ញមានគោលដៅពិតប្រាកដគឺបម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន និងជានាឲ្យប្រទេសជាតិមានសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍរួអង្វែង។

បច្ចុប្បន្ននេះព្រះរាជាណាចក្រកម្ពុជាបានកំពុងធ្វើដំណើរយ៉ាងស្វាហាប់លើមាគ៌ាប្រជាធិបតេយ្យ នីតិរដ្ឋ និងការអភិវឌ្ឍ ដោយជានាបានសុខសន្តិភាព ស្ថិរភាពនយោបាយ ការរីកចម្រើនខាងសេដ្ឋកិច្ច និងសង្គម ក្រោមពន្លឺនៃសុខសន្តិភាពដ៏ក្តីថ្នាំងថែង។ កិត្យានុភាពជាតិកាន់តែត្រូវបានលើកកម្ពស់ជាលំដាប់ និងបានដើរតួនាទីកាន់តែសកម្មនៅលើឆាកអន្តរជាតិ ទាំងនៅក្នុងក្របខណ្ឌតំបន់ និងពិភពលោក។ យើងការពារបានយ៉ាងរឹងមាំនូវខឿនឯករាជ្យអធិបតេយ្យ បូរណភាពទឹកដី ជាមួយនឹងការជំរុញអភិវឌ្ឍន៍ឲ្យមានវឌ្ឍនភាពជាលំដាប់ និងចាក់គ្រឹះកាន់តែរឹងមាំនូវដំណើរការលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការពង្រឹងនីតិរដ្ឋ។ ជំហានរីកលូតលាស់នេះ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈដំណើរការនៃការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានប្រព្រឹត្តិទៅតាមការកំណត់របស់រដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋ។

នៅក្នុងដំណាក់កាលនៃការរីកលូតលាស់យ៉ាងលឿននៅគ្រប់វិស័យ ព្រមគ្នានឹងការពង្រឹងការអនុវត្តនីតិរដ្ឋ ឲ្យកាន់តែមានប្រសិទ្ធភាព ទាមទារចាំបាច់ឲ្យមានការកែសម្រួលលើបញ្ហាមួយចំនួន ឲ្យស្របទៅនឹងស្ថានភាពជាក់ស្តែងនៃការវិវត្តន៍ទៅតាមសភាពការណ៍។ ហេតុនេះហើយ ទើបមានច្បាប់ខ្លះដែលបានបង្កើតឡើងតាំងពីពេលមុន ហើយដែលស្របទៅនឹងសភាពការណ៍នៅពេលនោះ មានចំណុចខ្លះមិនសមស្របឬមិនមានសង្គតិភាពជាមួយនឹងសភាពការណ៍ជាក់ស្តែង និងសំណូមពរការងារនាពេលនេះ ចាំបាច់ត្រូវធ្វើការកែសម្រួល។ ហេតុនេះហើយទើបទាមទារចាំបាច់ឲ្យត្រូវធ្វើវិសោធនកម្មទៅលើជំពូកខ្លះ ឬមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញ និងច្បាប់មួយចំនួន ដើម្បីជានាឲ្យការពង្រឹងបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ ការលើកកម្ពស់ បើកទូលាយលំហរនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិសេរីភាពរបស់ប្រជាជន ក៏ដូចជាការជំរុញការអភិវឌ្ឍប្រទេស ដែលជាផលប្រយោជន៍ជាសារវន្តរបស់ប្រជាជនយើង។

ការធ្វើវិសោធនកម្មច្បាប់ និងរដ្ឋធម្មនុញ្ញត្រូវបានបណ្តាប្រទេសទាំងអស់លើពិភពលោក តែងតែអនុវត្តជាប្រចាំ ដើម្បីឲ្យស្របគ្នាទៅនឹងសភាពការជាក់ស្តែងនីមួយៗ។ ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជាយើង ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញបានធ្វើចំនួន ៩ដង រួចមកហើយ។ ដូច្នេះ នេះមិនមែនជារឿងថ្មីសម្រាប់ប្រទេសកម្ពុជាយើងទេ ហើយវាមិនមែនជារឿងចម្លែកណាមួយ ដែលមិនធ្លាប់កើតមាននូវបណ្តាប្រទេសមួយចំនួនលើពិភពលោកនោះដែរ។

កន្លងមកនេះ អាស្រ័យដោយការធ្វើវិសោធនកម្មទៅលើមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញបានធ្វើឲ្យប្រទេសយើងជានាបាននូវសន្តិភាពស្ថិរភាពនយោបាយ និងបានរួមចំណែកលើកស្ទួយតម្លៃនៃប្រជាធិបតេយ្យនៅកម្ពុជា។

ផ្អែកលើស្មារតីនេះហើយ ទើបតម្រូវឲ្យមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់មួយចំនួន ជាបន្តបន្ទាប់ ហើយជាពិសេសគឺការធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញជាលើកទី១០។ គណបក្សប្រជាជនកម្ពុជាប្រកាន់ខ្ជាប់នូវគោលជំហរគោរពការពារដាច់ខាតនូវរដ្ឋធម្មនុញ្ញ ការពាររបបរាជានិយម ការពាររាល់សមិទ្ធផលសង្គមជាតិ ការពារ និងលើកស្ទួយជ្រោងខ្ពស់លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយមិនអនុញ្ញាតឲ្យកម្លាំងអមិត្តណាមួយមកបំផ្លិចបំផ្លាញបានឡើយ។ ការស្នើធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញនាពេលនេះ គឺក្នុងគោលបំណង និងឧត្តមគតិដូចដែលបានរៀបរាប់ខាងលើនេះ។ អ្វីៗទាំងអស់ដើម្បីផលប្រយោជន៍របស់ប្រជាជន។ អ្វីៗទាំងអស់ ដើម្បីភាពសុខសាន្តរបស់ប្រទេសជាតិ។ អ្វីៗទាំងអស់ ដើម្បីការអភិវឌ្ឍ។ អ្វីៗទាំងអស់ ដើម្បីភាពស្ថិតស្ថិរ គង់វង្ស នៃមាតុភូមិកម្ពុជា។ ប្រជាជនកម្ពុជាសូមគាំទ្រទាំងស្រុងនូវការធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញនៅពេលនេះ ដោយក្តីសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចតេជោ ហ៊ុន សែន** នឹងបន្តថែរក្សាបាននូវសុខសន្តិភាព ភាពសុខសាន្ត និងសុភមង្គលរបស់ប្រជាជន រួមជាមួយនឹងការរក្សាបានយ៉ាងរឹងមាំនូវសុខសន្តិភាព ដែលយើងទាំងអស់គ្នាកំពុងតែទទួលបាននាពេលបច្ចុប្បន្ន ៕

ព្រះមហាក្សត្រកម្ពុជា អំពាវនាវដល់ជនរួមជាតិ បន្តទប់ស្កាត់ការកាប់បំផ្លាញព្រៃឈើ និងបញ្ឈប់ការប្រមាញ់សត្វព្រៃ

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ បំផុត ស្តេចសព្វព្រះរាជហឫទ័យ យាងជាព្រះរាជាធិបតីប្រារព្ធព្រះរាជពិធី **«រុក្ខទិវា ៩ កក្កដា»**

នាព្រឹកថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២២ នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ក្នុងភូមិសំបួរមាស ឃុំស្វឹង ស្រុកបាណន់ ខេត្តបាត់ដំបង **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ បំផុត ស្តេចសព្វព្រះរាជហឫទ័យ យាងជាព្រះរាជាធិបតីប្រារព្ធព្រះរាជពិធី **«រុក្ខទិវា ៩ កក្កដា»** អញ្ជើញអមព្រះរាជដំណើរមាន **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា **សម្តេចក្រឡាហោម ស ខេង** ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្នាក់ដឹកនាំជាន់ខ្ពស់រាជរដ្ឋាភិបាល អង្គទូតនៃបណ្តាប្រទេសជាមិត្តប្រចាំកម្ពុជា ព្រះសង្ឃ ព្រះញាតិវង្សានុវង្ស មន្ត្រីរាជការ និងប្រជាពលរដ្ឋ ជាច្រើនរូប។

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី មានព្រះរាជឱង្ការថា ការដាំដើមឈើ គឺជាការវិនិយោគបៃតង លើធម្មជាតិ ដែលផ្តល់ពហុប្រយោជន៍សម្រាប់មនុស្សជាតិយើងទាំងអស់គ្នា សត្វ និងភពផែនដី។ ព្រះអង្គក៏បានឧទ្ទិសពិធី រុក្ខទិវា ឱ្យស្ថិតក្នុងបេះដូង របស់បងប្អូនជនរួមជាតិគ្រប់ៗរូប និងក្លាយជាប្រពៃណីនៃការរួមសាមគ្គីគ្នាដាំដើមឈើគ្រប់ប្រភេទ រួមគ្នាថែរក្សាការពារ និងអភិវឌ្ឍន៍ធនធាន ព្រៃឈើ សត្វព្រៃដ៏មានតម្លៃរបស់យើងឱ្យបានគង់វង្សរហូតតទៅ។ព្រះករុណាព្រះមហាក្សត្រ រំលឹកថា ពិធីរុក្ខទិវា ត្រូវបានរៀបចំឡើងតាំងពីសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំដ៏ថ្លៃថ្លាបំផុតរបស់ ព្រះករុណា ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី បានបន្តប្រារព្ធពិធី រុក្ខទិវា នៅតាមរាជធានី-ខេត្តទូទាំងប្រទេស។

ព្រះករុណាព្រះមហាក្សត្រ បានមានព្រះរាជបន្ទូលថា ប្រជាជនកម្ពុជាបានយល់ច្រើនដណាស់ថា ព្រៃឈើ ជាសម្បត្តិធម្មជាតិដ៏មហាសាល សម្រាប់ជីវិតមនុស្ស និងសត្វរស់នៅលើភពផែនដីយើងនេះ។ ព្រៃឈើ និងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើចូលរួមចំណែកយ៉ាងសំខាន់ ដល់គ្រប់ទិដ្ឋភាពនៃគោលដៅអភិវឌ្ឍ ធានាសន្តិសុខស្បៀង និងបណ្តាញសុវត្ថិភាព លើកកម្ពស់ជីវភាព ផ្តល់មុខរបរ និងកាត់បន្ថយភាពក្រីក្រ លើកកម្ពស់អាហារូបត្ថម្ភ និងសុខភាព រក្សានិរន្តរភាពផលិតកម្ម កំណើនសេដ្ឋកិច្ច សមភាពបរិយាបន្ន និងភាពជាដៃគូ ធនធានទឹក ការពារធនធាន ជលផល សន្តិសុខថាមពល ថែរក្សាជីវចម្រុះ និងប្រព័ន្ធមជ្ឈដ្ឋានដីគោក ជួយគាំទ្រនិរន្តរភាពទីក្រុង ទប់ស្កាត់ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ដូចនេះ ការបាត់បង់ព្រៃឈើគ្រប់ប្រភេទ អាចបណ្តាលឱ្យមានទឹកជំនន់ ខ្យល់កន្ត្រាក់រន្ធះ និងការរាំងស្ងួត ដែលបានធ្វើឱ្យទីតម្កល់ទឹកនានា សម្រាប់តម្រូវការរបស់មនុស្ស សត្វ ត្រូវរីងស្ងួត ឈានទៅរកការបាត់បង់ប្រាក់ចំណូលសត្វព្រៃ ធនធានមច្ឆជាតិគ្រប់ប្រភេទ ហើយអាចបង្កឱ្យមានភាពរហោស្ថាន និងការធ្លាក់ ចុះគុណភាព ដីផងដែរ។

ព្រះករុណា ព្រះមហាក្សត្រ បានអំពាវនាវចំពោះព្រះសង្ឃ អាជ្ញាធរដែនដី វិស័យឯកជន និងបងប្អូនជនរួមជាតិនៅទូទាំងប្រទេស ចូលរួមដាំដើមឈើគ្រប់ប្រភេទ ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ក្នុងនោះក៏មានដើមត្នោតផងដែរ នៅតាមទីវត្តអារាម ទីសាធារណៈ និងរមណីយដ្ឋានតាមដងផ្លូវលំ ផ្លូវជាតិ តាមដងប្រឡាយ ភូមិដ្ឋាននានា និងតាមភ្លឺស្រែចម្ការ ដើម្បីបានម្លប់ ជាជម្រកមនុស្ស សត្វ ហើយបាន ជាឈើ សំណង់ អុស ធ្យូង បង្កើនជីវជាតិដីកសិកម្ម ជួយទប់កម្លាំង ខ្យល់កន្ត្រាក់ ស្រូបឧស្ម័នកាបូនិច និងបម្រែបម្រួលធាតុអាកាស ផងដែរ។ ជាពិសេសគួរយកចិត្តទុកដាក់រួមគ្នាបង្កើតគំនិតថ្មីមួយទុកជាទម្លាប់ ដើម្បីឱ្យគួស្រករដែលទើបរៀបអាពាហ៍-ពិពាហ៍ ចូលរួមដាំដើមឈើទុកជាអនុស្សាវរីយ៍នៅសួនអាពាហ៍ពិពាហ៍ សួនព្រៃឈើ លំហែកម្សាន្ត ដែលបានបង្កើតឡើងដោយរដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលព្រៃឈើ ឱ្យបានគ្រប់ៗគ្នា នៅតាមទីប្រជុំជនស្រុក ក្រុង ឃុំ សង្កាត់ ភូមិ ។

ព្រះករុណា ព្រះមហាក្សត្រ ក៏បានអំពាវនាវឱ្យបងប្អូនជនរួមជាតិ ជួយទប់ស្កាត់ និងបញ្ចប់ការកាប់ឈើ ការកាប់រាន ដុត ឈូស ឆាយដីព្រៃ ការបរបាញ់ ការដាក់អន្ទាក់ចាប់សត្វព្រៃដោយខុសច្បាប់ ហើយចូលរួមថែរក្សាការពារព្រៃឈើ ជាពិសេស ការពារភ្លើងឆេះព្រៃនៅតាមតំបន់ដែលបងប្អូនរស់នៅ ដើម្បីរក្សាការពារឱ្យបាននូវធនធានព្រៃឈើ សម្រាប់កូនចៅរបស់យើងជំនាន់នេះ និងជំនាន់ក្រោយៗទៀត ។ ព្រះអង្គក៏បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះប្រទេសជាមិត្ត អង្គការ ជាតិ-អន្តរជាតិនានា ដែលបាននិងកំពុងយកចិត្តទុកដាក់ក្នុងការចូលរួម ជួយដល់ការងារដាំដើមឈើ ការថែរក្សា និងការពារធនធានព្រៃឈើ-សត្វព្រៃ ក៏ដូចជា ការចូលរួមក្នុងការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច សង្គម កម្ពុជាក្នុងពេលអតីតកាល និងបច្ចុប្បន្ន ហើយសូមមេត្តាជួយបន្តទៅ មុខទៀត ដើម្បីសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា៕

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

សេចក្តីជូនដំណឹង
ស្តីពីលទ្ធផលនៃសន្និបាតគណៈកម្មាធិការកណ្តាលខសាមញ្ញ
របស់គណបក្សប្រជាជនកម្ពុជា

សន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញនៃ **គណបក្សប្រជាជនកម្ពុជា** បានប្រព្រឹត្តទៅនៅថ្ងៃទី ១៦ និងថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានគណបក្ស សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានកិត្តិយសគណបក្ស សម្តេចក្រឡាហោម **ស ខេង** អនុប្រធានគណបក្ស សម្តេចវិបុលសេនាកក្តី **សាយ ឈុំ** អនុប្រធានគណបក្ស សម្តេចពិជ័យសេនា **ឡេវ ឡាញ់** អនុប្រធានគណបក្ស លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** អនុប្រធានគណ-បក្ស និងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល។ អញ្ជើញចូលរួមក្នុងសន្និបាតនេះមានសមាជិក សមាជិកានៃគណៈកម្មាធិការកណ្តាលចំនួន ៧៤៣ រូប លើបរិមាណរួម ៨៦៥រូប និងមន្ត្រីគណបក្សជាសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់នៃគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្រុមការងារគណបក្សចុះមូលដ្ឋានជាច្រើនរូបទៀត ធ្វើឱ្យចំនួនសមាជិកចូលរួមសរុបមាន ៣៤៧៤ រូប។

សន្និបាតបានប្រព្រឹត្តទៅតាមរបៀបវារៈដែលបានកំណត់ ក្នុងស្មារតីឯកភាព ប្រជាធិបតេយ្យ និងការទទួលខុសត្រូវខ្ពស់ចំពោះឧត្តមប្រយោជន៍ជាតិ និងប្រជាជន ហើយបានសម្រេចលទ្ធផលដូចខាងក្រោម ៖

១. អង្គសន្និបាតបានពិភាក្សា និងអនុម័ត របាយការណ៍ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងទិសដៅការងាររបស់គណបក្សឆ្ពោះទៅការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខ ។

២. អង្គសន្និបាតធ្វើការកត់សម្គាល់ប្រកបដោយមោទនភាពចំពោះជោគជ័យនៃដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ កន្លងទៅ ដែលបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាសអព្យាក្រឹត សន្តិសុខ របៀបរៀបរយ គ្មានអំពើហិង្សា និងការគំរាមកំហែង។ ជោគជ័យនេះបានឆ្លុះបញ្ចាំងឱ្យឃើញអំពីភាពចាស់ទុំនយោបាយនៃដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ដោយអនុវត្តរបបបោះឆ្នោតពហុបក្សជាប់លាប់តាមពេលវេលាកំណត់ រក្សាបានភាពចម្រុះខាងនយោបាយនៅគ្រប់ថ្នាក់តាំងពីថ្នាក់ជាតិដល់មូលដ្ឋាន។

អង្គសន្និបាតសម្តែងការគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋានឃុំ សង្កាត់ទូទាំងប្រទេស ដែលបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាយ៉ាងច្រើនលើសលប់ ធ្វើឱ្យគណបក្សបានទទួលជ័យជម្នះដ៏ត្រចះត្រចង់ដោយទទួលបានសំឡេងគាំទ្រស្មើនឹង ៧៤,៣២% នៃសំឡេងឆ្នោតបានការសរុប ទទួលបានអាសនៈក្រុមប្រឹក្សាឃុំ សង្កាត់ ៨០,៦៧% និងទទួលតំណែងជាមេឃុំ ចៅសង្កាត់ ៩៩,៧៦%។

តាមរយៈជ័យជម្នះនេះបានឆ្លុះបញ្ចាំងនូវការផ្តល់យុត្តិធម៌របស់ប្រជាពលរដ្ឋចំពោះសច្ចភាពនៃការដឹកនាំដ៏ត្រឹមត្រូវរបស់គណបក្សប្រជាជនកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន និងបង្ហាញច្បាស់ថាប្រជាជនគាំទ្រសន្តិភាព គាំទ្រការអភិវឌ្ឍ និងគាំទ្រសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

អង្គសន្និបាតកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារគណបក្សចុះមូលដ្ឋាន គណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់អង្គការចាត់តាំង មន្ត្រី និងសកម្មជនរបស់គណបក្ស ដែលបានប្រឹងប្រែងគ្រប់លទ្ធភាព យកអស់កម្លាំងកាយ កម្លាំងចិត្ត លះបង់ពេលវេលា និងធនធានផ្ទាល់ខ្លួន ផ្សារភ្ជាប់ជាមួយមូលដ្ឋាន ជាមួយប្រជាជន ក្នុងស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុងដ៏រឹងមាំ ដើម្បីបម្រើបុព្វហេតុរបស់គណបក្ស។

៣. អង្គសន្និបាតបានពិនិត្យពិភាក្សាយ៉ាងល្អិតល្អន់ អំពីកត្តាធំៗនៃជ័យជម្នះរបស់គណបក្សដែលត្រូវយកចិត្តទុកដាក់ពង្រឹង និងពង្រីកបន្តទៀត ព្រមទាំងចំណុចខ្វះខាតនានាដែលត្រូវខិតខំដោះស្រាយ និងកែលម្អដើម្បីពង្រឹងជំនឿរបស់ប្រជាជនចំពោះការដឹកនាំរបស់គណបក្ស។ ក្នុងស្មារតីនេះ គណបក្សបន្តជំរុញការអនុវត្តវាល់ទិសដៅជាអាទិភាពទាំងឡាយដោយឆន្ទៈមោះមុត ឱ្យទទួលបានលទ្ធផលល្អប្រសើរ គឺការពង្រឹងសន្តិភាព ស្ថិរភាព-នយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពភូមិ ឃុំ សង្កាត់, ការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ការពារខឿនសុខភាពប្រជាជន, ការស្តារ អភិវឌ្ឍសេដ្ឋកិច្ច សង្គម និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនក្រោយវិបត្តិជំងឺកូវីដ-១៩ និងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

អង្គសន្និបាតគាំទ្រពេញទំហឹងការខិតខំរបស់រាជរដ្ឋាភិបាលដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា និងរក្សាអំណាចទិញរបស់ប្រាក់រៀលសំដៅរក្សាលំនឹងនៃជីវភាពប្រជាជន ក្នុងបរិការណ៍ត្រូវទទួលរងសម្ពាធពីការវិវត្តប្រកបដោយគ្រោះថ្នាក់នៃសភាពការណ៍អន្តរជាតិ។ ជំរុញការអនុវត្តគោលនយោបាយគាំពារសង្គម ជាពិសេសការជួយគាំពារជនក្រីក្រ និងជនរងគ្រោះដោយជំងឺកូវីដ-១៩, ការជំរុឡើងបៀវត្សរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ការកែសម្រួលប្រាក់សោធននិវត្តន៍មន្ត្រីរាជការ និងអតីតយុទ្ធជន, ការអនុវត្តប្រាក់សោធននិវត្តន៍សម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ និងការជំរុឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត។ ព្រមជាមួយនេះ សន្និបាតគាំទ្រ និងចូលរួមសកម្មដើម្បីសម្រេចនូវ "គម្រោងសម្តេចតេជោ **ហ៊ុន សែន** សម្រាប់សកម្មភាពមីន" ក្រោមមូលបទ "ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម"។

៤. អង្គសន្និបាតបញ្ជាក់ជាឱឡារិកនូវការគាំទ្រសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាបេក្ខភាពនាយករដ្ឋមន្ត្រីសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា និងគាំទ្រ ឯកឧត្តម **ហ៊ុន ម៉ាណែត** ជាបេក្ខភាពនាយករដ្ឋមន្ត្រីសម្រាប់ពេលអនាគត។

៥. អង្គសន្និបាតគាំទ្រទាំងស្រុងសំណើវិសោធនកម្មលើកទី ១០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សំដៅបម្រើឧត្តមប្រយោជន៍របស់ជាតិ គឺ ៖ (ទី១)-ការធានាឱ្យស្ថាប័នកំពូលរបស់ជាតិ ជាពិសេស អំណាចនីតិ-ប្រតិបត្តិដែលមានបេសកកម្មចម្បងក្នុងការដឹកនាំការងារទូទៅរបស់រដ្ឋ មានដំណើរការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយនិរន្តរភាពនៅគ្រប់កាល:ទេស: និង (ទី២)- ការធានាការពារ និងថែរក្សាឱ្យបាននូវសន្តិភាព សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិនៅគ្រប់កាល:ទេស: ដើម្បីជាគ្រឹះសម្រាប់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ និងសេចក្តីសុខសាន្តរបស់ប្រជាជនកម្ពុជា។

៦. អង្គសន្និបាតមានការសង្ឃឹមជឿជាក់ថា គ្រប់គណបក្សនយោបាយ អង្គការនៃសង្គមស៊ីវិល និងមជ្ឈដ្ឋានផ្សេងៗទៀតក្នុងសង្គមនឹងបន្តធ្វើសហប្រតិបត្តិការជាមួយគ្នាយ៉ាងជិតស្និទ្ធ តាមគោលការណ៍នៃលទ្ធិ-ប្រជាធិបតេយ្យ សំដៅចូលរួមចំណែកដ៏សកម្មដល់ការបង្កើតបរិយាកាសនយោបាយល្អប្រសើរ ឆ្ពោះទៅការបោះ

ឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅឆ្នាំ២០២៣ ខាងមុខ។ ជាមួយគ្នានេះ យើងត្រូវទប់ស្កាត់រាល់សកម្មភាពប្រទូសរ៉ាយទាំងឡាយទោះចេញពីប្រភពណាក្តី ដែលចង់បំផ្លាញសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ញុះញង់បង្កការបែកបាក់ក្នុងសង្គមជាតិ និងរារាំងដំណើរការអភិវឌ្ឍន៍នៃព្រះរាជាណាចក្រកម្ពុជាដែលកំពុងតែឈានទៅមុខយ៉ាងស្វាហាប់លើមាគ៌ាប្រជាធិបតេយ្យ និងនីតិរដ្ឋ។

៧. អង្គសន្និបាតអំពាវនាវដល់ក្រុមការងារគណបក្សចុះមូលដ្ឋាន គណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក មន្ត្រី សមាជិក សមាជិកានៃគណបក្សទាំងមូល សូមបន្តលើកកម្ពស់ប្រពៃណីស្នេហាជាតិ និងសាមគ្គី-ភាពឯកភាពផ្ទៃក្នុង បន្តជំរុញសកម្មភាពដោយឥតថមថយប្រកបដោយប្រសិទ្ធភាពទាំងការអនុវត្តកម្មវិធីនយោបាយ ទាំងការកសាងពង្រឹងគណបក្ស ទាំងការផ្សារភ្ជាប់ជាមួយមូលដ្ឋាន ខិតខំបម្រើប្រជាជនអស់ពីចិត្តពីថ្លើម តាមតួនាទី និងភារកិច្ចរបស់ខ្លួន ដែលឆ្លើយតបទាំងស្រុងទៅនឹងសំណូមពរ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន។

សូមអំពាវនាវដល់ជនរួមជាតិទាំងមូលទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស សូមបន្តរួមសាមគ្គីគ្នាជាឆ្អឹងមួយ ក្រោមដំបូលរដ្ឋធម្មនុញ្ញ និងម្លប់ដ៏ត្រជាក់នៃ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត និងរួមសាមគ្គីជុំវិញរាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ដើម្បីថែរក្សាសន្តិភាព ការពាររាល់សមិទ្ធផលនៃសង្គមជាតិ និងបន្តកសាងមាតុភូមិជាទីស្នេហានៃយើងឱ្យកាន់តែរីកចម្រើនស្រស់បំព្រងឡើង។ ព្រមជាមួយនេះ សូមជនរួមជាតិបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលបានដាក់ចេញ ជាពិសេសវិធានការ "៣ការពារ ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឲ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន។

អង្គសន្និបាតប្រគល់ភារកិច្ចជូនគណៈអចិន្ត្រៃយ៍ ដើម្បីដឹកនាំអនុវត្តសេចក្តីសម្រេចនៃសន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញនេះឱ្យទទួលបានលទ្ធផលល្អប្រសើរ។

ថ្ងៃអាទិត្យ ៨រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២២

គណៈកម្មាធិការកណ្តាល

សន្និបាត
គណៈកម្មាធិការកណ្តាល នីតិកាលទី៦នៃគណបក្ស

សម្តេចតេជោ ហ៊ុន សែន៖ បោះឆ្នោតឱ្យគណបក្សប្រជាជន ជាការបោះឆ្នោតឱ្យខ្លួនឯង ដើម្បីរក្សាសេចក្តីសុខ សន្តិភាព និងការអភិវឌ្ឍ

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរ ទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០២២

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបសំណេះសំណាល និងផ្តល់ជំបូន្មានមួយចំនួន ជូនដល់គណៈប្រតិភូកីឡា អាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games)

✲ នៅព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០២២ ដែលបានប្រារព្ធឡើងនៅទីតាំងអាងទឹក ត្រពាំងថ្ម ភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា ការព្រលែងកូនត្រី និងត្រីមេពូជនាថ្ងៃនេះ គឺជារឿងល្អមួយ សម្រាប់បង្កើនផលត្រីសម្រាប់ប្រជាពលរដ្ឋ ហើយការលែងត្រីមិនមែនធ្វើតែក្នុងទិវាមច្ឆជាតិ ១កក្កដា នោះទេ គឺអាចធ្វើរាល់ថ្ងៃ ឲ្យតែមានកន្លែងព្រលែង(ទឹក) និងមានពូជត្រីសម្រាប់ព្រលែង ។ ជាមួយគ្នានេះ ការដាំកូនឈើក៏ដូចគ្នាដែរ មិនមែនធ្វើតែនៅក្នុងរុក្ខទិវា ៩កក្កដា នោះទេ គឺអាចធ្វើបានរាល់ថ្ងៃ។ សម្តេចតេជោ ក៏បានបន្តក្រើនរំលឹកដល់អភិបាលខេត្តជុំវិញបឹងទន្លេសាប ទាំងអស់ត្រូវអនុវត្តន៍ឱ្យបានច្បាស់លាស់ លើការកាត់ឆ្វៀលដីតំបន់អភិរក្សនៅបឹងទន្លេសាប ជូនប្រជាពលរដ្ឋដែលកាន់កាប់យូរឆ្នាំមកហើយនោះ តាមការដាក់ចេញនូវបទបញ្ជាកន្លងទៅ។ សម្តេចតេជោបានអំពាវនាវឲ្យប្រជាពលរដ្ឋនៅបឹងទន្លេសាប កុំឱ្យមានការកាប់ទន្ទ្រានយកដីអភិរក្សតំបន់២ និង៣បន្តទៀត។

សម្តេចតេជោ ហ៊ុន សែន បានប្រកាស និងចេញបទបញ្ជាឱ្យអាជ្ញាធរមីន និងវិស័យឯកជន ចូលរួមក្នុងការដោះមីននៅឃុំប៉ោយចារ និងតំបន់អាងត្រពាំងថ្ម ឱ្យអស់នៅចុងឆ្នាំ២០២២នេះ ដើម្បីប្រែក្លាយតំបន់នេះទៅជាតំបន់សុវត្ថិភាពដែលទាក់ទាញភ្ញៀវទេសចរ និងដើម្បីសុវត្ថិភាពប្រជាពលរដ្ឋនៅក្នុងតំបន់នេះ។ ទោះបីក្នុងតម្លៃណាក៏ដោយ ត្រូវដោះមីននៅតំបន់នេះឲ្យអស់ដើម្បីធានាសុវត្ថិភាពរបស់ប្រជាពលរដ្ឋរបស់យើង។ សម្តេចតេជោបានស្នើឲ្យ ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ដាក់ចូលទៅក្នុងថវិកាជាតិឆ្នាំ២០២៣-២០២៤ សម្រាប់ការងារបោសសំអាតមីន។ ដោយសារមានតំបន់ខ្លះត្រូវការថវិកាត្រឹម ៥ម៉ឺនដុល្លារប៉ុណ្ណោះសម្រាប់ដោះមីន តែយើងគ្មានលុយចាំទៅសុំបរទេសឲ្យជួយ។ ដូចនេះយើងអាចប្រើប្រាស់ថវិការបស់យើង ដើម្បីបញ្ចប់ការដោះមីនហើយប្រកាសភូមិ ឃុំដែលគ្មានមីនតែម្តងដើម្បីរក្សាសុវត្ថិភាពប្រជាពលរដ្ឋរបស់យើង។ ជាមួយគ្នានេះសម្តេចតេជោក៏អំពាវនាវដល់វិស័យឯកជននានា និងសប្បុរសជនដែលមានបំណងចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បីបោសសំអាតមីននៅកម្ពុជា និងគ្រាប់មិនទាន់ផ្ទុះ ដើម្បីកម្ពុជាឈានទៅគ្មានគ្រាប់មីននៅឆ្នាំ២០២៥ ។ សម្តេចតេជោបញ្ជាក់ថា អ្វីដែលសំខាន់ជាងនេះទៀតគឺការឈានទៅបញ្ចប់នូវសោកនាដកម្មលើប្រជាជនកម្ពុជា ដែលស្លាប់ និងរបួសដោយគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដែលជាឃាតករលាក់មុខដែលនៅសេសសល់លើទឹកដីកម្ពុជា ដើម្បីធានាថា កន្លែងហ្នឹង គឺជាកន្លែងដែលមិនមែនជាកន្លែងដែលភ័យខ្លាចតែជាស្មាមញញឹមជំនួសឲ្យទឹកភ្នែកពីអតីតកាលរបស់ប្រជាជន និងជាភាពសុខសាន្ត និងស្នាមញញឹមរបស់ប្រជាជនកម្ពុជា។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងអំណរគុណប្រជាពលរដ្ឋដែលបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជា ដើម្បីសន្តិភាព និងការអភិវឌ្ឍ សេចក្តីសម្រេចចិត្តរបស់ប្រជាពលរដ្ឋ ដែលបានចូលរួមបោះឆ្នោតរយៈពេលកន្លងទៅ ហើយបោះឆ្នោតឱ្យគណបក្សប្រជាជនមានអត្ថន័យច្បាស់លាស់ ជាសារបញ្ជាក់ថាគាំទ្រសន្តិភាព និងការអភិវឌ្ឍ»។ សម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ កន្លងមកថ្មីៗនេះគឺជាការប្រកួតប្រជែងនៅក្នុងដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស។ **សម្តេចតេជោ ហ៊ុន សែន** បន្តថា៖ «ការបោះឆ្នោតឱ្យគណបក្សប្រជាជនគឺជាការបោះឆ្នោតឱ្យខ្លួនឯងដើម្បីរក្សាសេចក្តីសុខ សន្តិភាព បើមានសន្តិភាពទើបអាចអភិវឌ្ឍន៍បាន កុំចាំដល់ពេលបាត់សន្តិភាព ទើបនាំគ្នាស្រែករកសន្តិភាព។ ពិបាកណាស់សង្គ្រាមឆ្នាំ១៩៧០ ប្រជាជនរបស់យើងស្លាប់ និងរបួស មិនតិចទេ»។

សម្តេចតេជោ ហ៊ុន សែន បានបន្តអំពាវនាវដល់ប្រជាពលរដ្ឋត្រូវទៅទទួលយកនូវការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ឲ្យបានគ្រប់ៗគ្នាបន្ថែមទៀត ទាំងដែលអ្នកមិនទាន់ចាក់ដូសមូលដ្ឋាន និងអ្នកដែលដល់វេនត្រូវចាក់ដូសជំរុញ។ ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋនេះ គឺធ្វើឡើងដោយឥតគិតថ្លៃអ្វីទាំងអស់ បើទោះបីត្រូវចាក់ដល់ដូសទី២០ក៏ដោយ។ សម្តេចតេជោ បានចាត់ទុកថា ដើម្បីការពារ និងធានាដល់សុខភាពរបស់ប្រជាពលរដ្ឋអំពីស្ថានភាពធ្ងន់ធ្ងរ

***សម្តេចតេជោ ហ៊ុន សែន** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំដើម្បីពិភាក្សាលើកិច្ចការនានាត្រៀមឆ្ពោះទៅរកការប្រកួតប៉ារ៉ាហ្គេម និងស៊ីហ្គេម ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅឆ្នាំ២០២៣ ខាងមុខ*

នៃជំងឺកូវីដ១៩នោះ វិធីតែមួយគត់ គឺចាក់វ៉ាក់សាំងបង្ការ ខណៈជំងឺនេះមិនទាន់បញ្ចប់នៅឡើយទេ។ **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា **«ដើម្បីធានាថា ប្រជាពលរដ្ឋរបស់យើងទទួលបាននូវសុវត្ថិភាព បើទោះបីជាឆ្លងក៏មិននាំទៅដល់ការស្លាប់ ឬភាពធ្ងន់ធ្ងរ រឿងតែមួយគត់ គឺចាក់វ៉ាក់សាំង។ ហើយខ្ញុំសូមបញ្ជាក់ថា កុំថាឡើយដូសទី៣ ដូសទី៤ ដូសទី៥ សូម្បីតែដូសទី២០ ក៏រាជរដ្ឋាភិបាលអត់យកលុយពីបងប្អូនប្រជាពលរដ្ឋនោះដែរ ខ្ញុំប្រើពាក្យថា ស្រោចវ៉ាក់សាំង»**។

✵ នៅព្រឹកថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជួបសំណេះសំណាល និងផ្តល់ដំបូន្មានមួយចំនួន ជូនដល់គណៈប្រតិភូកីឡា អាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games) មុននឹងពួកគេចេញទៅប្រកួតកីឡាពិការអាស៊ាន ឬអាស៊ានប៉ារ៉ាហ្គេម លើកទី១១ នៅទីក្រុងសូឡូ ប្រទេសឥណ្ឌូនេស៊ី នៅវិមានសន្តិភាព។ **សម្តេចតេជោ ហ៊ុន សែន** បានស្នើឱ្យកីឡាករ កីឡាការិនី ដែលចេញទៅប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមទាំងអស់គឺ «ត្រូវធ្វើយ៉ាងណាធានានូវក្រឹតក្រមក្បួនខ្នាតនៃការប្រកួត ចៀសវាងនូវការបំពានណាមួយទៅលើលក្ខន្តិកៈនៃការប្រកួត»។ ចៀសវាងដាច់ខាតមិនឱ្យមានការប្រើប្រាស់នូវសារធាតុ ដែលមានការហាមឃាត់សម្រាប់ផ្នែកកីឡា ដែលនាំឱ្យមានការបាត់បង់នូវកិត្តិយសរបស់ប្រទេសជាតិ ។ សម្តេចតេជោបានលើកឡើងថា «មេដាយមាស មេដាយប្រាក់ ឬ អត់មេដាយ មិនសំខាន់ទេ តែការបំផ្លាញដោយសារការប្រើប្រាស់សារធាតុដែលហាមឃាត់ គឺជាការបំផ្លាញមុខមាត់ប្រទេសជាតិដ៏ធំ» ព្រោះមេដាយដែលក្រុមទាំងមូលបានទៅទទួល មិនគ្រប់គ្រាន់ដើម្បីនឹងប៉ះប៉ូវមុខមាត់ដែលខូចខាតដោយសារតែការប្រើប្រាស់សារធាតុញៀន ឬ សារធាតុដែលត្រូវហាមឃាត់នៅក្នុងវិស័យកីឡានោះទេ។

សម្តេចតេជោ ហ៊ុន សែន បានបង្ហាញពីមហិច្ឆតាបញ្ចប់ឱ្យបានបញ្ហាមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅត្រឹមឆ្នាំ២០២៥។ សម្តេចតេជោ បានថ្លែងថា រាជរដ្ឋាភិបាល នឹងប្រើប្រាស់ថវិការដ្ឋរួមជាមួយថវិកាសប្បុរសជន និងប្រជាជនកម្ពុជា សម្រាប់ការបោសសំអាតគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដើម្បីប្រែក្លាយកម្ពុជាសូន្យគ្រាប់មីន។ **សម្តេចតេជោ ហ៊ុន សែន** ធ្វើការអំពាវនាវដល់វិស័យឯកជន ដើម្បីចូលរួមក្នុងការងារដោះមីន ធ្វើយ៉ាងណាឱ្យប្រទេសកម្ពុជាយើងក្លាយទៅជាប្រទេសដែលអត់មានមីន តាមការគ្រោងទុកដែលយើងបានស្នើសុំទៅ។ ដោយសារតែយើងបានសុំការពន្យាពេលម្តងហើយម្តងទៀតឥឡូវយើងដោះបាននោះលើទំហំដីភាគច្រើនហើយ ក៏ប៉ុន្តែកន្លែងខ្លះដូចជានៅមានចំនួនតិចតួចនៅតាមភូមិ ឃុំ ដូច្នេះយើងត្រូវរៀបចំដើម្បីដោះមីន ដោយប្រើថវិកាជាតិទម្លាក់ឱ្យ ជាពិសេសធានារ៉ាប់រងថា កន្លែងហ្នឹងគឺជាកន្លែងមិនមានការភ័យខ្លាច,មានតែស្មាមញញឹមជំនួសឱ្យទឹកភ្នែកពីអតីតកាលរបស់ប្រជាជន ។ សម្តេចតេជោក៏បានអំពាវនាវឱ្យមានការចូលរួមទាំងផ្នែករាជរដ្ឋាភិបាល និងផ្នែកវិស័យឯកជនដើម្បីចូលរួមនៅក្នុងវគ្គផ្តាច់ព្រ័ត្រ «ដំណើរឆ្ពោះទៅកម្ពុជាសូន្យមីន» នៅឆ្នាំ២០២៥ ។ សម្តេចតេជោបានបញ្ជាក់ថា៖ «ខ្ញុំចង់វែផ្តាច់ព្រ័ត្រ ដើម្បីឱ្យបញ្ហាមីននៅកម្ពុជាត្រូវបានបញ្ចប់នៅឆ្នាំ២០២៥ ដោយប្រើចលនាជាតិរបស់យើងដើម្បីបញ្ចប់វា»។ សម្តេចតេជោក៏បានអំពាវនាវឱ្យពលរដ្ឋចូលរួមវិភាគទានបន្ថែមទៀតដែលជាការបង្ហាញពីចលនាជាតិមួយដើម្បីសុវត្ថិភាពប្រជាជន គ្មានអ្នកស្លាប់ និងរបួសដោយសារមីន ហើយប្រជាពលរដ្ឋនឹងបានទទួលដីធ្លីទៅបង្កបង្កើនផលដោយស្មាមញញឹម ផ្តល់នូវស្មាមញញឹមសម្រាប់ប្រជាជនបំបាត់នូវការភ័យខ្លាចទាំងអស់។

សម្តេចតេជោ ហ៊ុន សែន បានបន្តអំពាវនាវឱ្យប្រជាពលរដ្ឋបន្តយកចិត្តទុកដាក់ការពារខ្លួន ពិសេសត្រូវតែទៅទទួលយកវ៉ាក់សាំងការពារខ្លួនមានតែវ៉ាក់សាំងទេដែលអាចការពារយើងបាន។ សម្តេចតេជោបានគូសបញ្ជាក់ថា គ្មានការបិទរោងចក្រ បិទសាលារៀន ឬបិទផ្សារនោះទេ, សូមបងប្អូនជាកម្មករ កម្មការិនី ជាអាជីវករ បន្តធ្វើការកសុីដោយភាពសុខសាន្ត អ្វីដែលបងប្អូនត្រូវធ្វើគឺទៅទទួលយកវ៉ាក់សាំងតាមការកំណត់របស់ក្រសួងសុខាភិបាល, កិច្ចការពារខ្លួនកាន់តែល្អប្រសើរជាការល្អសម្រាប់យើង។ ម្ចាស់រោងចក្រនៅកន្លែងនីមួយៗត្រូវតែគិតអំពីសុវត្ថិភាពនៃកម្មកររបស់ខ្លួន, ជំរុញលើកទឹកចិត្តឱ្យពួកគេបានទៅទទួលវ៉ាក់សាំងតាមការកំណត់និងត្រួតពិនិត្យឱ្យបានច្បាស់លាស់ ។ ជាមួយគ្នានេះរដ្ឋមន្ត្រីតាមក្រសួងនានាក៏ត្រូវតាមពិនិត្យអំពីបុគ្គលិករបស់ខ្លួន, បណ្តាក្រុមហ៊ុននានាត្រូវតែគិតពីបុគ្គលិកក្រុមហ៊ុនរបស់ខ្លួនទៅចាក់ដល់ដូសទីប៉ុន្មាន ហើយត្រូវជំរុញលើកទឹកចិត្តឱ្យទៅចាក់ ។ គ្មានអ្វីខ្លាំងជាងវ៉ាក់សាំង និងល្អជាងវ៉ាក់សាំងទេ។ **សម្តេចតេជោ ហ៊ុន សែន** បន្តថា រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលនឹងខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ ដ៏កាចសាហាវនេះ ព្រោះនៅពេលយើងមានសុវត្ថិភាពផ្នែកសុខភាពនឹងធ្វើឱ្យសង្គមគ្រួសារយើងមានជីវភាពរីកចម្រើន សង្គមជាតិក៏មានការអភិវឌ្ឍ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានបំពេញខាតប្រមាណជាង ១០០លានដុល្លារសហរដ្ឋអាមេរិក ដោយក្នុងអំឡុងពេលកូវីដ១៩ ប្រេងឥន្ធនៈបានចុះថ្លៃ នៅពេលដែលកូវីដ១៩ ចាប់ផ្តើមថមថយ ហើយសេដ្ឋកិច្ចសង្គមដំណើរការឡើងវិញ ប្រេងឥន្ធនៈក៏បានឡើងថ្លៃបន្តិច ប៉ុន្តែដោយសារសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការដាក់ទណ្ឌកម្មទៅវិញទៅមក បានធ្វើឱ្យតម្លៃប្រេងឥន្ធនៈ ដែលហៅថា វិបត្តិថាមពលបានកកើតពេញបន្ទុកនៅលើពិភពលោករួចស្រេចទៅហើយ។ សម្តេចតេជោក៏បានអំពាវនាវដល់ប្រជាពលរដ្ឋ និងស្ថាប័នរដ្ឋទាំងអស់ ត្រូវចូលរួមសន្សំសំចៃអគ្គិសនីឱ្យបានគ្រប់ៗគ្នា ស្របពេលដែលអគ្គិសនីកម្ពុជា ក៏បានប្រឹងប្រែងទប់ និងកុំឱ្យខាតដោយសារការកើនឡើងថ្លៃប្រេងឥន្ធនៈដែលកើតមានទូទាំងពិភពលោក

ដោយសារវិបត្តិសង្គ្រាម និងការដាក់ទណ្ឌកម្ម។

✵ នៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំ ដើម្បីពិភាក្សាលើកិច្ចការនានាត្រៀមឆ្ពោះទៅរកការប្រកួតប៉ារ៉ាហ្គេម និងស៊ីហ្គេម ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅឆ្នាំ២០២៣ ខាងមុខ ដែលកិច្ចប្រជុំសហព័ន្ធទាំងពីរខាងលើ នឹងត្រូវធ្វើឡើងរយៈពេល ៣ថ្ងៃ គឺចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកក្កដា ២០២២ រាជធានីភ្នំពេញ។ **សម្តេចតេជោ ហ៊ុន សែន** មានសេចក្តីរីករាយដោយបានជួបជុំមហាគ្រួសារកីឡាជាតិ និងកីឡាតំបន់អាស៊ីអាគ្នេយ៍ក្នុងកិច្ចប្រជុំ ដ៏មានសារៈសំខាន់នេះ និងស្វាគមន៍ប្រតិភូកីឡាក្រុមប្រឹក្សាស៊ីហ្គេម និងក្រុមប្រឹក្សាអាស៊ានប៉ារ៉ាហ្គេមដែលបានអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ និងក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ានប៉ារ៉ាសម្រាប់រយៈពេល ៣ ថ្ងៃ នៅព្រះរាជាណាចក្រកម្ពុជា។ សម្តេចតេជោ ថ្លែងអំណរគុណ ប្រតិភូកីឡាបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដែលបានគាំទ្រកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេម (SEA Games) និងអាស៊ានប៉ារ៉ាហ្គេម (ASEANParaGames) នៅឆ្នាំ២០២៣នៅព្រះរាជាណាចក្រកម្ពុជា។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ឆ្នាំ២០២២-២០២៣ នេះគឺជាឆ្នាំដ៏មានសារៈសំខាន់ សម្រាប់ព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាប្រធានអាស៊ាន និងជាប្រធានក្រុមប្រឹក្សាកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម។ ក្នុងនាមជាប្រធានប្តូរវេននៃស្ថាប័នតំបន់ទាំងពីរ កម្ពុជាមានការតាំងចិត្តខ្ពស់ឈរលើគោលការណ៍កិច្ចសហប្រតិ បត្តិការសន្តិសហវិជ្ជមាន និងស្មើមុខ ស្មើមាត់ រួមចំណែកដល់ការ ដោះស្រាយរាល់បញ្ហាប្រឈមនានា ដែលអាចកើតឡើងជាយថាហេតុនៅក្នុងតំបន់ ដើម្បីធានាសុខសន្តិភាព សុខដុមនីយកម្ម និងភាពជាដៃគូគ្រប់ជ្រុងជ្រោយ សំដៅជំរុញល្បឿននៃការអភិវឌ្ឍសម្រាប់ជោគវាសនា និងវិបុលភាពរួម។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា វិស័យកីឡាដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យទំនាក់ទំនងអន្តជាតិ។ ការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម រៀងរាល់២ឆ្នាំម្តង ឆ្លុះបញ្ចាំងឱ្យឃើញនូវការរឹតចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងរាជរដ្ឋាភិបាលនិងប្រជាជននៃប្រទេសជាសមាជិកទាំងអស់។ វិស័យកីឡាក៏ជាឱកាសផ្តល់នូវការផ្លាស់ប្តូរទាំងបច្ចេកទេស និងបទពិសោធន៍ក្នុងការប្រកួតកីឡា ដែលជាមរតកវប្បធម៌ និងជាសិល្បៈការពារខ្លួនរបស់ប្រជាជាតិនីមួយៗ។ ការប្រកួតជាលក្ខណៈអន្តរជាតិនេះ ក៏ជាការបំផុសស្មារតីមហាជនឱ្យកាន់តែស្រឡាញ់ និងគាំទ្រវិស័យកីឡា ហើយក៏ជាការលើកកម្ពស់កិត្តិសព្ទកីឡារបស់ប្រទេសសមាជិកនីមួយៗឱ្យកាន់តែល្បីល្បាញនៅលើឆាកអន្តរជាតិ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា កីឡាក៏រួមចំណែកដល់ការរក្សាបានសុខភាពល្អ ដែលជាកត្តាកំណត់នៃផលិតភាពសេដ្ឋកិច្ច។ ប្រជាពលរដ្ឋដែលមានសុខភាពល្អ ងាយចាប់យកចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ និងមានការតាំងចិត្តខ្ពស់ក្នុងការបង្កើនមូលធនមនុស្ស ដែលរួមចំណែកដល់ការផ្គត់ផ្គង់កម្លាំងពលកម្ម មានគុណភាពខ្ពស់។ សកម្មភាពអប់រំកាយ និងកីឡាមានសារៈសំខាន់ ក្នុងការពង្រឹងសុខភាពផ្លូវកាយរឹងមាំ លើកកម្ពស់សុខភាពផ្លូវចិត្ត ជ្រះថ្លា និងការងារបង្កើនបញ្ញាឈ្លាសវៃព្រមទាំងលើកកម្ពស់គុណភាពជីវិត និងសុភមង្គលក្នុងគ្រួសារ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជាបានរង់ចាំរយៈពេល ៦៤ឆ្នាំ ទើបសម្រេចចិត្តយកឆ្នាំ២០២៣ ធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម។ កម្ពុជាបានខកខានចាប់យកឱកាសនេះជាច្រើនលើកច្រើនសារ ដើម្បីត្រៀមខ្លួនប្រកបដោយសមត្ថភាពពេញលេញ និងកៀរគរធនធានចាំបាច់គ្រប់គ្រាន់សម្រាប់រៀបចំការប្រកួតកីឡាថ្នាក់តំបន់ដ៏ធំនេះឱ្យបានល្អ និងរលូន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ក្នុងនាមជា ម្ចាស់ផ្ទះសម្រាប់ការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ឆ្នាំ២០២៣ កម្ពុជាមានមហិច្ឆតារៀបចំទទួលស្វាគមន៍ភ្ញៀវជាតិ និងអន្តរជាតិប្រកបដោយភាពកក់ក្តៅ បដិសណ្ឋារកិច្ចល្អ និងសេវាល្អសម្រាប់គ្រប់ប្រតិភូកីឡា និងភ្ញៀវជាតិ-អន្តរជាតិ ដើម្បីទទួលបានបទពិសោធន៍ល្អបំផុត ក្នុងការចូលរួមការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ឆ្នាំ២០២៣ នៅកម្ពុជា។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា នយោបាយគ្មានស្តង់ដារពិតប្រាកដទេ ប៉ុន្តែកីឡាមានស្តង់ដារសកលពិតប្រាកដ មានច្បាប់កីឡាតែមួយ មានបទបញ្ជាការប្រកួតកីឡាតែមួយ និងមានគោលដៅតែមួយ គឺការកសាងពិភពលោកមួយល្អប្រសើរ និងការរួមចំណែកយ៉ាងសំខាន់ដល់សុខសន្តិភាព និងស្ថិរភាពសង្គម។

ក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានដាក់ចេញគោលការណ៍ និងផ្តល់អនុសាសន៍គន្លឹះមួយចំនួនដើម្បីត្រៀមធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍កីឡាដ៏ធំ ជាប្រវត្តិសាស្ត្រនេះឱ្យទទួលបានជោគជ័យខ្ពស់រួមមាន៖ **១**-គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ឆ្នាំ ២០២៣ ត្រូវយកចិត្តទុកដាក់លើគ្រប់មុខសញ្ញាគ្រប់គ្រងព្រឹត្តិការណ៍សំខាន់ៗឱ្យបានរួចរាល់និងទាន់ពេលពិសេសការងារដែលត្រូវការពេលយូរ ត្រូវចាប់ផ្តើមពីពេលនេះតទៅ ដូចជាការជួសជុលកែលម្អទីលានប្រកួតការរៀបចំប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាជីអឹមអេស (GMS) ការរៀបចំពិធីបើក និងពិធីបិទព្រមទាំងការរៀបចំកន្លែងស្នាក់នៅ ហូបចុក និងដឹកជញ្ជូនជាដើម។ ជាមួយនេះត្រូវជំរុញឱ្យបានខ្លាំងថែមទៀត ក្នុងការអភិវឌ្ឍកម្រិតបច្ចេកទេសកីឡារួមទាំងកីឡាល្បុក្កតោខ្មែរ និងកីឡាយុទ្ធគុនឥណ្ឌូណេស៊ី ដែលមានឈ្មោះថា ស៊ីឡាត់ (Silat) ដែលទទួលបានការឯកភាព ជួយពីឯកឧត្តមរដ្ឋមន្ត្រីការពារជាតិនៃប្រទេសឥណ្ឌូនេស៊ី និងកីឡាយូដូ ពីឯកឧត្តមអតីតឯកអគ្គរដ្ឋទូតជប៉ុន, **២**- ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជនចូលរួមយុទ្ធនាការផ្សព្វផ្សាយ និងយុទ្ធនាការលាងសម្អាតផ្ទះ និងសង្គមយើងតាមរយៈយុទ្ធនាការ "ប្រជាជនម្នាក់លេងកីឡាមួយមុខយ៉ាងតិចប្រចាំជីវិត" "កម្ពុជាស្អាត បដិសណ្ឋារកិច្ចល្អ សេវាល្អ" " កម្ពុជាកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងកាត់បន្ថយឥទ្ធិពលគ្រឿងញៀន" និង "កីឡារស់ក្នុងសន្តិភាព" ឱ្យបានជុំសជុល ទាំងក្នុង និងក្រៅប្រទេស, **៣**-ក្រសួងអប់រំយុវជន និងកីឡា ពិនិត្យលទ្ធភាពពន្យារវិស្សមកាលតូចក្នុងអំឡុងពេលចូលឆ្នាំខ្មែរប្រពៃណីជាតិរហូតដល់ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០២៣ ដើម្បីផ្តល់ឱកាសឱ្យសិស្ស-និស្សិតចូលរួមបម្រើការងារជាអ្នកស្ម័គ្រចិត្ត និងចូលរួមអបអរសាទរលើកទឹកចិត្តកីឡាករ កីឡាការិនីជាតិ-អន្តរជាតិ និងទី**៤**-សូមអំពាវនាវបណ្តាប្រទេសសមាជិកស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម មេត្តាផ្តល់នូវការគាំទ្រក្នុងគ្រប់ទម្រង់តាមដែលអាចធ្វើទៅបាន ដើម្បីឱ្យការរៀបចំការប្រកួតកីឡា ស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ឆ្នាំ ២០២៣ ទទួលបានជោគជ័យ ៕

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ៖ ការពារដាច់ខាតសន្តិភាព ស្ថិរភាពនយោបាយ និងជំរុញការអភិវឌ្ឍគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពឱ្យបានល្អប្រសើរ

***សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ របស់ខេត្តត្បូងឃ្មុំ និងផ្សព្វផ្សាយខ្លឹមសារសន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញ*

នៅព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារគណបក្សចុះជួយខេត្តត្បូងឃ្មុំ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ របស់ខេត្តត្បូងឃ្មុំ និងផ្សព្វផ្សាយខ្លឹមសារសន្និបាតគណៈកម្មាធិការកណ្តាលវិសាមញ្ញកាលថ្ងៃទី ១៦ និង១៧ ខែកក្កដា ឆ្នាំ២០២២ នៅមន្ទីរគណបក្សខេត្តត្បូងឃ្មុំ ។ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានថ្លែងថា តាមរយៈនៃលទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥នេះ បានបង្ហាញឱ្យឃើញច្បាស់ពីជ័យជំនះដ៏ធំធេងរបស់គណបក្សប្រជាជនកម្ពុជាក្នុងក្របខណ្ឌខេត្ត ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់ឈានទៅរកជ័យជម្នះថ្មីទៀត ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នាថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៣ខាងមុខ។

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន បានស្នើឱ្យមន្ត្រីគណបក្សទាំងអស់ ត្រូវបន្តរៀបចំការងារឱ្យបានល្អ និងឆាប់រហ័សសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ខាងមុខ ដោយត្រូវពិនិត្យ កែសម្រួលក្រុមការងារគណបក្សចុះមូលដ្ឋាន ឱ្យមានបរិមាណ និងលទ្ធភាពសមស្រប និងមានការទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ចដែលបានប្រគល់ឱ្យ រក្សាការផ្សារភ្ជាប់ជាមួយប្រជាជន ស្វែងយល់ពីទុក្ខលំបាកប្រជាជន ខិតខំដោះស្រាយ និងសំណូមពររបស់ប្រជាជន បន្តជួបសំណេះសំណាលថ្លែងអំណរគុណប្រជាពលរដ្ឋដែលបោះឆ្នោតគាំទ្រគណបក្សជូនគណបក្សប្រជាជនកម្ពុជា។

ដើម្បីសម្រេចការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្រនេះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានធ្វើការណែនាំដោយយកចិត្តទុកដាក់អនុវត្តភារកិច្ចមួយចំនួនរួមមាន៖ ការពារដាច់ខាតសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ទប់ស្កាត់រាល់ការប៉ុនប៉ងបង្កចលាចលរបស់ពួកប្រឆាំងជ្រុលនិយម, បន្តជំរុញយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនប្រជាជនដោយឥតគិតថ្លៃ និងការអនុវត្តន៍វិធានការសុខភាពនានា ដើម្បីបង្កើនភាពស៊ាំក្នុងសហគម រាំងស្កាត់ការឆ្លងរាលដាលជាថ្មីនៃជំងឺនេះ, ជំរុញការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីស្តារ និងកំណើនជំរុញសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយជំងឺកូវីដ-១៩តាមគន្លងប្រក្រតីភាពថ្មី, ជំរុញការអភិវឌ្ឍគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពឱ្យបានល្អប្រសើរ និងខិតខំដោះស្រាយជម្លោះដីធ្លីក្រៅប្រព័ន្ធតុលាការឱ្យបានល្អឆាប់រហ័ស, បន្តអនុវត្តន៍គោលនយោបាយគាំពារសង្គម ជាពិសេសជួយគាំពារជនក្រីក្រ ជនងាយរងគ្រោះដោយជំងឺកូវីដ-១៩ ជាដើម។

ក្នុងឱកាសនោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** បានសម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ដែលវត្តមាននៅទីនេះក៏ដូចជាមន្ត្រីយើងទាំងអស់ដែលនៅក្នុងក្រុមការងារគណបក្សចុះជួយមូលដ្ឋាន និងគណៈកម្មាធិការគណបក្ស គ្រប់ថ្នាក់ ពិសេសថ្នាក់ឃុំ សង្កាត់ និងភូមិក្នុងទូទាំងខេត្តដែលលះបង់អស់កម្លាំងកាយ ស្មារតី និងសំភារៈ ខិតខំបំពេញភារកិច្ច ដែលគណៈអចិន្ត្រៃយ៍បានដាក់ចេញក្នុងសេចក្តីសម្រេចស្តីពីផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិទី៥រហូតសម្រេចបាននូវជ័យជំនះដ៏ធំធេងជូនគណបក្ស សម្រាប់ជាមូលដ្ឋានគ្រឹះឆ្ពោះទៅដណ្តើមជោគជ័យថ្មីថែមទៀត នាពេលខាងមុខ៕

ឯកឧត្តម ហ៊ុន ម៉ាណែត ៖ បន្តរួបរួមគ្នាជាកម្លាំងមហាសាមគ្គីជាតិខ្មែរ ដើម្បីបន្តថែរក្សាការពារជាតិខ្មែរយើងឱ្យបានរីកចម្រើន និងស្ថិតនៅជាអមតៈ

*ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីកាត់ឫសសីមាព្រះវិហារថ្មី និង សម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តប្រវត្តិសាស្ត្រ **«វត្តមរតកតេជោបុរីស្វរៈ»** ស្ថិតនៅភូមិ ធម្មជាតិ សម្តេចតេជោ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ*

នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០២២ ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីកាត់ឫសសីមាព្រះវិហារថ្មី និង សម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តប្រវត្តិសាស្ត្រ **«វត្តមរតកតេជោបុរីស្វរៈ»** ស្ថិតនៅភូមិ ធម្មជាតិ សម្តេចតេជោ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ព្រមទាំងបានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួបលើកទី១៤ នៃការ ចុះបញ្ជីប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក។

ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** បានថ្លែងថា លក្ខណៈពិសេសរបស់ទីអារាមនេះ គឺស្ថិតនៅក្នុងតំបន់ដែលកាលពីអតីតកាល គឺជាតំបន់គ្មានប្រជាជនរស់នៅ គ្មានហេដ្ឋារចនាសម្ព័ន្ធ និងសំបូរទៅដោយគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ប៉ុន្តែសព្វថ្ងៃនៅតំបន់នេះមានវត្តអារាម សាលារៀន មណ្ឌលសុខភាព និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗជាច្រើនទៀត បម្រើឱ្យសេចក្តីត្រូវការក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ក៏ដូចជាផ្នែកមួយនៃការការពារនូវកេរដំណែលបេតិកភណ្ឌវប្បធម៌ខ្មែរ ដែលមានតម្លៃលេចធ្លោជា សកល ព្រមជាមួយនឹងការបង្កើតនូវសុខដុមនីយកម្មរវាងប្រាសាទបុរាណ បរិស្ថាន និងសហគមន៍ប្រជាពលរដ្ឋ។

ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** បានថ្លែងទៀតថា រាជរដ្ឋាភិបាលកម្ពុជា បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍ការពារបូរណភាពទឹកដីដោយមិនឱ្យបាត់បង់សូម្បី១មីលីម៉ែត្រ ហើយក៏មិនរំលោភបំពានប្រទេសជិតខាងសូម្បី១មីលីម៉ែត្រដូចគ្នា និងប្តេជ្ញាធានាការបន្តអភិវឌ្ឍនៅតំបន់ព្រំដែន និងកែប្រែតំបន់អតីតសមរភូមិឱ្យប្រែក្លាយជាតំបន់ពោរពេញដោយសុខសន្តិភាព ស្ថិរភាព និងកំណើនសេដ្ឋកិច្ច ។ ឯកឧត្តមបន្តថា សម្តេចតេជោ នឹងនៅបន្តដឹកនាំធានាការពារដាច់ខាតនូវបូរណភាពរបស់ប្រាសាទព្រះវិហារ និងតំបន់ជុំវិញ ដែលជាកេរដំណែលវប្បធម៌ប្រវត្តិសាស្ត្រ ព្រមជាមួយនឹងការបន្តខិតខំថែរក្សាអភិរក្សស្របតាមបទដ្ឋានបច្ចេកទេសរបស់អង្គការ UNESCO ។ ក្នុងទស្សនវិស័យប្រកបដោយ

យុទ្ធសាស្ត្រនេះ សម្តេចតេជោនាយករដ្ឋមន្ត្រីបានបើកឱកាសឱ្យប្រជាពលរដ្ឋរស់នៅតាមតំបន់ព្រំដែន បង្កើតជាភូមិឋានដោយបានរៀបចំជាតំបន់អភិវឌ្ឍន៍ ដែលមានការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ សាលារៀន វត្តអារាម ផ្សារលក់ដូរ និងប្រព័ន្ធទឹកភ្លើង ដើម្បីសម្រួលដល់ជីវភាពរបស់ ប្រជាជន ហើយស្ថានភាពនៃការអភិវឌ្ឍន៍នៅតាមតំបន់ព្រំដែនបែបនេះ ក៏បានដើរតួនាទីមួយយ៉ាងសំខាន់ផងដែរក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងល្អរវាង ប្រជាជន និងប្រជាជននៅជាប់តំបន់ព្រំដែនឱ្យបានស្និទ្ធស្នាលតាមរយៈសកម្មភាពផ្លាស់ប្តូរសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ជាដើម។ ឯកឧត្តមបណ្ឌិត បានបន្តថា ការកសាងពីចំណុចសូន្យដោយបាតដៃទទេ វាគឺជាការលំបាកណាស់ទៅហើយ ប៉ុន្តែការថែរក្សាដើម្បីធានាបាននូវចីរភាពនៃ សមិទ្ធផលទាំងអស់នោះ គឺកាន់តែលំបាកខ្លាំងបំផុត។ ឯកឧត្តមក៏អំពាវនាវប្រជាជនកម្ពុជាទាំងនៅក្នុងមូលដ្ឋាននេះ ក៏ដូចជានៅទូទាំងប្រទេសបន្ត រួបរួមគ្នាជាកម្លាំងមហាសាមគ្គីជាតិខ្មែរ ដើម្បីបន្តថែរក្សាការពារជាតិខ្មែរយើងឱ្យបានរីកចម្រើន និងស្ថិតនៅជាអមតៈសម្រាប់អ្នកជំនាន់ក្រោយតទៅមុខទៀត៕

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** អនុប្រធានគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា ខេត្តស្វាយរៀង រួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការ បានអញ្ជើញប្រគេនទៀនព្រះវស្សាដល់ព្រះសង្ឃគង់ចាំព្រះវស្សាអស់ត្រីមាស ចំនួន៩វត្ត ក្នុងខេត្តស្វាយរៀង ដែលធ្វើឡើងនៅវត្តព្រៃឆ្លាក់ ស្ថិតនៅសង្កាត់ព្រៃឆ្លាក់ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។ លោកជំទាវ-កិត្តិសង្គហបណ្ឌិត មានប្រសាសន៍ថា ពិធីនេះអាចប្រព្រឹត្តទៅបានដោយសារតែប្រទេសជាតិមានសុខសន្តិភាពពេញលេញ ក្រោមការដឹកនាំប្រកបដោយកិត្តិបណ្ឌិតរបស់ **សម្តេចតេជោ ហ៊ុន សែន** ប្រទេសឲ្យមានការអភិវឌ្ឍ និងមានការរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យព្រះពុទ្ធសាសនាក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ។

ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **កែ គឹមយ៉ាន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តបន្ទាយមានជ័យ បានអញ្ជើញជាអធិបតីប្រារព្ធខួបលើកទី១៥ ទិវាអតីតយុទ្ធជនកម្ពុជា នៅខេត្តបន្ទាយមានជ័យ។ ឯកឧត្តម ថ្លែងថា រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខ និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា តែងតែគិតគូ និងយកចិត្តទុកដាក់ជានិច្ចពីការរស់នៅ ជីវភាព និងសុខទុក្ខបងប្អូនអតីតយុទ្ធជន និងក្រុមគ្រួសារទាំងអស់។

ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកលើកដែក បានអញ្ជើញជាអធិបតីប្រារព្ធមីទ្ទិញរំលឹកខួបលើកទី៧១ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨មិថុនា ១៩៥១-២៨ មិថុនា ២០២២) ដោយមានការចូលរួមពីសមាជិក សមាជិកា គណៈ-កម្មាធិការគណបក្សក្នុងជួរគណបក្ស ស្រុក-ឃុំ ក្រុមការងារស្ត្រី និងយុវជនជុំវិញស្រុក ប្រមាណ ៥០០ នាក់ នៅទីស្នាក់ការបក្សស្រុកលើកដែក ខេត្តកណ្តាល។

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទបានអញ្ជើញដឹកនាំកិច្ចប្រជុំលើកទី៣៥ របស់ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ តាមប្រព័ន្ធអនឡាញ ។ សូមបញ្ជាក់ថា ប្រជាពលរដ្ឋនៅតាមតំបន់ជនបទ ទទួលបានទឹកស្អាតប្រើប្រាស់ និងប្រតិបត្តិអនាម័យបានប្រមាណ ៨០% រួចហើយ ។

សកម្មភាពសមាជិកវរជួសតា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ថោង ខុន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អនុប្រធានទី១ ក្រុមការងារគណបក្សប្រជាជន កម្ពុជាខេត្តកំពង់ធំ និងជាប្រធានក្រុមការងារចុះជួយស្រុកបារាយណ៍ និងស្រុកតាំងគោក បានអញ្ជើញដឹកនាំការរៀបចំអង្គមិទ្ធិញខួប ៧១ឆ្នាំ នៃការបង្កើតគណបក្សប្រជាជនកម្ពុជា ជាមួយថ្នាក់ដឹកនាំ និងសមាជិក-សមាជិកាគណបក្សនៅទូទាំងស្រុកបារាយណ៍ និងស្រុកតាំងគោក។ ជ័យជម្នះរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គឺដោយសារគណបក្សមានសាមគ្គីផ្ទៃក្នុងរឹងមាំ បូករួមនឹងកិច្ចខិតខំរបស់គណបក្ស និងគុណសម្បត្តិជាច្រើនរបស់ គណបក្សប្រជាជនកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាល ដែលមាន**សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខ។

ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ង៉ន សូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និងឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង បានអញ្ជើញប្រគេនទៀនព្រះវស្សា និងជួបសំណេះសំណាលជាមួយលោកយាយលោកតា នៅក្នុងវត្តថ្លូវ ស្ថិតក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ឯកឧត្តមបានថ្លែងថា កត្តាសុខ-សន្តិភាពបាននាំមកការអភិវឌ្ឍប្រទេសជាតិជាបន្តបន្ទាប់ មិនថា វិស័យពុទ្ធចក្រ និងអាណាចក្រឡើយ។

ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ខៀវ កាញារីទ្ធ** សមាជិកគណៈ-កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាប្រធានក្រុមការងារគណបក្សចុះជួយមូលដ្ឋានស្រុកកោះសូទិន ខេត្តកំពង់ចាម បានអញ្ជើញជួបសំណេះសំណាល ជាមួយបងប្អូនប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងប្រធានក្រុមប្រឹក្សាឃុំ ពាមប្រធោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ឯកឧត្តមបានផ្តាំផ្ញើដល់ក្រុមប្រឹក្សាឃុំមេប៉ុស្តិ៍ត្រូវបន្តកែលម្អការងារឲ្យបានកាន់តែប្រសើរត្រូវមានសាមគ្គី-ភាពផ្ទៃក្នុងរឹងមាំ បង្ហាញសមត្ថភាពការងាររបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋបានឃើញនូវរាល់កិច្ចការងារបម្រើប្រជាពលរដ្ឋ។

ឯកឧត្តម **ង្រុំ សុខា** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានថ្លែងបើកសិក្ខាសាលា ស្តីពី **"រដ្ឋាភិបាលឌីជីថល"** ដែលរៀបចំឡើងដោយកិច្ចសហការរវាងសាលាភូមិន្ទរដ្ឋបាលនៃក្រសួងមុខងារសាធារណៈកម្ពុជា និងវិទ្យាស្ថានមុខងារសាធារណៈសិង្ហបុរី ដោយមានការសម្របសម្រួលពីមូលនិធិ Temasek អន្តរជាតិ កាលពីព្រឹកថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២ថា៖ «ការដឹកនាំកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីកសាងទម្រង់រដ្ឋបាលមួយ ដើរឱ្យទាន់នឹងការវិវត្តប្រែប្រួលឆាប់រហ័ស នៃបច្ចេកវិទ្យាទំនើបក្នុងសម័យបដិវត្តន៍ឧស្សាហកម្ម ៤.០ តួយ៉ាងដូចជារដ្ឋាភិបាលឌីជីថល គឺទាមទារនូវការផ្លាស់ប្តូរផ្នត់គំនិត ដើម្បីពង្រឹងភាពជាអ្នកដឹកនាំ និងកសាងអភិវឌ្ឍធនធានមនុស្ស សំដៅបង្កើតឱ្យបាននូវរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចល្អ ក្នុងផ្នែកសាធារណៈ និងផ្នែកឯកជន ដោយមានការចូលរួមពីប្រជាពលរដ្ឋ»។

ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុត សំហោង** សមាជិកគណៈ-កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ បានអញ្ជើញដឹកនាំការប្រារព្ធទិវាពិភពលោកដើម្បីសុវត្ថិភាព និងសុខភាពការងារក្រោមប្រធានបទ «ធ្វើសកម្មភាពរួមគ្នាដើម្បីកសាងវប្បធម៌សុវត្ថិភាព និងសុខភាពជាវិជ្ជមាន» ដែលជាយុទ្ធនាការអន្តរជាតិ រៀបចំឡើងដោយរដ្ឋាភិបាល សមាគមនិយោជក និងសហជីព នៃបណ្តាប្រទេសសមាជិកអង្គការអន្តរជាតិខាងការងារ (ILO) នៅលើសកលលោក ជារៀងរាល់ឆ្នាំ ដោយមានអ្នកចូលរួមសរុបជាង ៧០០នាក់ មកពីតំណាងរោងចក្រ ទេសចរណ៍ សណ្ឋាគារ សំណង់ សិប្បកម្ម ជាដើម ដែលរៀបចំធ្វើឡើងនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

សកម្មភាពសមាជិកវរជួសតា-ព្រឹទ្ធសតា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សាយ សំអាល់** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ បានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារសាមគ្គីជាមួយបងប្អូនខ្មែរអ៊ីស្លាម នៅឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **តឹកវ៉ែត សំរេច** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ឯកឧត្តម **គួច ចំរើន** អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ជាក្រុមការងារចុះមូលដ្ឋានខេត្តព្រះសីហនុ និងបងប្អូនខ្មែរអ៊ីស្លាម ជាច្រើនរូបទៀត។

ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០២២ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាស្រុកបាភ្នំ ឯកឧត្តម **ស្បោង សារ៉ាត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ខេត្តព្រៃវែង បានអញ្ជើញជាអធិបតី ក្នុងពិធីប្រកាសបំពេញបន្ថែមអនុប្រធានគណបក្សសមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការគណបក្សស្រុកបាភ្នំ សរុបចំនួន ៧ រូប។ ឯកឧត្តមបានថ្លែងថា ការបំពេញបន្ថែមសមាជិករបស់យើងនាពេលនេះ ដើម្បីឲ្យពួកគាត់រួមចំណែកបំពេញការងារតាមតួនាទី ភារកិច្ច និងបំពេញកម្លាំងដឹកនាំរបស់គណបក្សស្រុក ដើម្បីឈានទៅដណ្តើមប្រៀបឈ្នះនៅពេលបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រនាឆ្នាំ ២០២៣ ខាងមុខ។

ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តមកិត្តិបណ្ឌិត **ហ៊ីង ប៊ុនហៀង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកកណ្តាលស្ទឹង និងលោកជំទាវ **ប៉ែន ចន្ថី** និងឯកឧត្តម **គុយ សុផល** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង និងលោកជំទាវបានអញ្ជើញជួបសំណេះសំណាល ជាមួយយុវជនក្រុងដូនកែវ ខេត្តតាកែវ។ ឯកឧត្តមបានបញ្ជាក់ថា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ប្រទេសយើងរក្សាបាននូវសុខសន្តិភាពពេញលេញខាងនយោបាយ សន្តិសុខរឹងមាំ ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចសង្គមកិច្ច សាមគ្គី ឯកភាពជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ជាពិសេសលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការរីកចម្រើន។

ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុនឆាង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្ត និងទទួលជួយស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រធានគណៈកម្មការទី១០ និងជាអ្នកនាំពាក្យព្រឹទ្ធសភាបានអញ្ជើញជាអធិបតីភាពក្នុងពិធីអបអរសាទរដល់បេក្ខជនគណបក្សប្រជាជនកម្ពុជា ដែលទទួលបានការគាំទ្រយ៉ាងច្រើនលើសលប់ពីសំណាក់ប្រជាជន តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២។

ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ជាម ប៉ែរ** អ្នកតំណាងរាស្ត្រអនុប្រធានទី១ ក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង និងជាប្រធានក្រុមការងារជួយឃុំព្រៃដើមថ្នឹង រួមជាមួយលោកបណ្ឌិត **លី រិទ្ធិ** អនុប្រធានក្រុមការងារជួយឃុំព្រៃដើមថ្នឹង និងលោកឧកញ៉ា **កែវ សម្បត្តិ** បានអញ្ជើញនាំយកទៀនវស្សា និងទេយ្យទាន ប្រគេនវត្តព្រៃដើមថ្នឹងជើង និងវត្តព្រៃដើមថ្នឹងត្បូង ដែលរួមមាន៖ទៀនវស្សាចំនួន ២គូរ,បច្ច័យកសាងវត្ត ក្នុងមួយវត្ត ៥០០.០០០រៀល, ប្រគេនព្រះសង្ឃ១១អង្គ ក្នុង១អង្គ ៣០.០០០រៀល លោកតាអាចារ្យ ២នាក់ ក្នុង១នាក់ ៣០.០០០រៀល, ជូនថវិកាលោកយាយលោកតាចំនួន ១២០នាក់ ក្នុង១នាក់ ១០.០០០រៀល, អង្ករចំនួន២០០គីឡូក្រាម, មីចំនួន ១០កេះ ,ទឹកត្រី ចំនួន១០យួរ, ទឹកសុទ្ធវីតាល់ ចំនួន ១០កេះ ,ថ្នាំដុសធ្មេញ ២យួរធំ សរុបថវិកាអស់ចំនួន ៤.៦៥៥.០០០រ (បួនលានប្រាំមួយរយហាសិបប្រាំពាន់រៀលគត់) ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ម៉ៅ ធនិន** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ខេត្តកំពត បានអញ្ជើញជាអធិបតី ក្នុងពិធីប្រកាសសុពលភាព សមាជិកក្រុមប្រឹក្សាឃុំ អាណត្តិទី៥ សម្រាប់ឃុំតេជោអភិវឌ្ឍន៍ និងឃុំត្រពាំងភ្លាំង ស្រុកឈូក។ ឯកឧត្តមថ្លែងថា ដើម្បីជាកិច្ចឆ្លើយតបនឹងការផ្តល់ទំនុកចិត្ត តាមរយៈការបោះឆ្នោតគាំទ្រថ្មីៗនេះ មេឃុំត្រូវផ្តល់ក្តីសុខសាន្តជាអចិន្ត្រៃយ៍ ជូនពលរដ្ឋមូលដ្ឋានរបស់ខ្លួន ឱ្យបានកក់ក្តៅបំផុត។ អំណាចបានមកពីរដ្ឋ និងប្រជាជនចាំបាច់ត្រូវតែបម្រើរដ្ឋ បម្រើប្រជាជន ធ្វើយ៉ាងណាកុំឱ្យពលរដ្ឋក្នុងមូលដ្ឋានរងទុក្ខ ព្រោះតែការប្រើអំណាចក្រៅច្បាប់។

ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ឃួង ស្រេង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជារាជធានី និងលោកជំទាវ រួមជាមួយមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋ ក្នុងរាជធានីភ្នំពេញ បានអញ្ជើញប្រគេនទៀនព្រះវស្សា ទេយ្យវត្ថុ បច្ច័យ និងគ្រឿងបរិក្ខារផ្សេងៗដល់ព្រះសង្ឃ ចំនួន ១៥១វត្ត ទូទាំងរាជធានីភ្នំពេញ នៅក្នុងបរិវេណវត្តច័ន្ទបុរីវង្ស ស្ថិតសង្កាត់សំរោង ខណ្ឌព្រែកព្នៅ។ ឯកឧត្តម បានថ្លែងថា បើគ្មានសុខសន្តិភាព គ្មានការរីកចម្រើនផ្នែកអាណាចក្រ ក៏មិនអាចធ្វើឲ្យផ្នែកពុទ្ធចក្ររីកចម្រើនបានដែរ។ សម្តេចតេជោ **ហ៊ុន សែន** មានគុណបំណាច់ដ៏ធំធេងធ្វើឲ្យប្រទេសជាតិមានការរីកចម្រើនលើគ្រប់វិស័យ។

ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុន ចាន់ដា** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ចាម បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសសុពលភាព សមាជិកក្រុមប្រឹក្សាឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម។ ឯកឧត្តម បានថ្លែងថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមកពីគណបក្សផ្សេងៗគ្នា ត្រូវខិតខំរួបរួមសាមគ្គីសហការធ្វើការជាមួយគ្នា ប្រកបដោយការទទួលខុសត្រូវ ដើម្បីបម្រើប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានល្អប្រសើរ។

ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ម៉ែន សំបូល** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តស្វាយរៀង បានអញ្ជើញជាអធិបតី ក្នុងពិធីប្រកាសសុពលភាព សមាជិកក្រុមប្រឹក្សាសង្កាត់ស្វាយរៀង អាណត្តិទី៥ ឆ្នាំ២០២២ ស្ថិតនៅសាលប្រជុំសាលាក្រុងស្វាយរៀង។ ឯកឧត្តមបានស្នើឲ្យក្រុមប្រឹក្សាសង្កាត់ អាណត្តិទី ៥ នេះ ក៏ដូចជា គណបក្សនយោបាយនានា និងប្រជាពលរដ្ឋទាំងអស់ ត្រូវខិតខំរួមគ្នាលើកកម្ពស់វប្បធម៌នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ដើម្បីរស់នៅ និងបំពេញការងារប្រកបដោយភាពសុខដុមរមនាក្នុងសង្គម សម្រាប់ជាមូលដ្ឋានក្នុងការធានាចីរភាពដំណើរការលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការបោះឆ្នោត និងការអភិវឌ្ឍសង្គមឲ្យកាន់តែមានការរីកចម្រើនបន្តទៀត។

ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុំ រាត្រី** ប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តបន្ទាយមានជ័យ បានដឹកនាំមន្ត្រីរាជការក្រោមឱវាទប្រគេនទៀនវស្សា និងទេយ្យទាន ជូនវត្តចំនួន២២ ក្នុងក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ ឯកឧត្តម បានគូសបញ្ជាក់ថា ពិធីសាសនានេះ អាចប្រព្រឹត្តទៅបានដោយសារតែប្រទេសជាតិមានសុខសន្តិភាពពេញលេញ ក្រោមការដឹកនាំប្រកបដោយកិត្តិបណ្ឌិតរបស់សម្តេចតេជោ **ហ៊ុន សែន** បានដឹកនាំប្រទេសឲ្យមានការអភិវឌ្ឍ និងមានការរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យព្រះពុទ្ធសាសនា ក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ៕

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិក-គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្ស ថ្នាក់កណ្តាល បានអញ្ជើញដឹកនាំគណៈប្រតិភូយុវជនគណបក្សប្រជាជនកម្ពុជា ថ្នាក់កណ្តាល ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម Shinzo Abe អតីត នាយករដ្ឋមន្ត្រីជប៉ុន នៅស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **សាន ឡូ៉ាត** សមាជិកគណៈ-កម្មាធិការកណ្តាល និងជាអនុប្រធានយុវជនគណបក្សថ្នាក់កណ្តាល បានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំពិភាក្សា និងស្តាប់បទបង្ហាញស្តីពីការ កសាងផែនការបណ្តុះបណ្តាលគ្រូឧទ្ទេស គ្រូជំនួយថ្នាក់រាជធានី ខេត្ត ដែលមានការអញ្ជើញចូលរួមពី ឯកឧត្តម **ហួត ហាក់** ប្រធានលេខាធិការដ្ឋាន ឯកឧត្តម **យស ផានីត្តា** ប្រធានផ្នែកបណ្តុះបណ្តាល ឯកឧត្តម **ឃុត ចាន់ជា៉ា** ប្រធានផ្នែកក្រសួង-ស្ថាប័ន ឯកឧត្តម **ពៅ ប៉ូលីណែល** ប្រធានផ្នែកផែនការយុទ្ធសាស្ត្រ ព្រមទាំងសមាជិក សមាជិកា និងក្រុមជំនាញទាំងបី នៃផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សថ្នាក់កណ្តាល នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា(វិមាន ៧មករា)។

ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ជ្រុន ថេ៉ាឡ៉ាត** សមាជិកគណៈកម្មាធិការកណ្តាល ជាអនុប្រធានយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានជនបង្គោលយុវជនថ្នាក់កណ្តាលចុះជួយស្រុកព្រៃឈរ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** បានអញ្ជើញចូលរួមជា អធិបតីក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ២៨.មិថុនា.១៩៥១-២៨.មិថុនា.២០២២ ដែលមានការ ចូលរួមពីឯកឧត្តម **ហ៊ុល ប៊ុនថា** លោកស្រី **យុង ខេមរា** អនុប្រធាន និងសមាជិក សមាជិកា ក្រុមការងារជនបង្គោលយុវជន គណៈកម្មាធិការគណបក្សស្រុក ក្រុមការងារយុវជនគណបក្សស្រុក គណៈកម្មាធិការឃុំទាំង១៥ ក្រុមការងារយុវជន និងក្រុមសកម្មជនយុវជនគណបក្សគ្រប់លំដាប់ថ្នាក់ សរុបចំនួន ៨៧០រូប នៅមន្ទីរគណបក្សស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ហួត ហាក់** សមាជិក-គណកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍ នៃយុវជនគណបក្ស ថ្នាក់កណ្តាល និងជាប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជន គណបក្សប្រជាជនកម្ពុជាប្រចាំទ្វីបអឺរ៉ុប បានដឹកនាំកិច្ចប្រជុំតាមដាន វឌ្ឍនភាពការងារ នៅតាមបណ្តាប្រទេស និងតំបន់នីមួយៗ នៃក្រុមការងារ រៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រចាំទ្វីបអឺរ៉ុប ដែលមានការចូលរួមសរុបចំនួន ៤០រូប នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា (វិមាន ៧មករា)។



ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **យស ផានីត្តា** សមាជិកគណៈកម្មាធិការកណ្តាលនិងជាប្រធានផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សថ្នាក់កណ្តាល បានអញ្ជើញដឹកនាំកិច្ចប្រជុំ តាមដានវឌ្ឍនភាពការងារប្រចាំខែមិថុនា ឆ្នាំ២០២២ និងផែនការ ឆ្ពោះទៅឆ្នាំ២០២៣របស់ផ្នែកបណ្តុះបណ្តាលនៃយុវជនគណបក្ស ថ្នាក់កណ្តាល ដែលមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា ក្រុមគ្រូឧទ្ទេស-គ្រូជំនួយ និងសមាជិក សមាជិកាក្រុមចំណុះទាំង៣ ផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សថ្នាក់កណ្តាល សរុបចំនួន ២៩រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ចាយ ឡូរិន** សមាជិក-គណៈកម្មាធិការកណ្តាល និងជាប្រធានផ្នែកយោសនាអប់រំ នៃយុវជន គណបក្សថ្នាក់កណ្តាល តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** និងលោកជំទាវបានអញ្ជើញដឹកនាំប្រតិភូក្រុមស្រាវជ្រាវប្រវត្តិសាស្ត្រនៃ ផ្នែកយោសនាអប់រំយុវជនគណបក្សថ្នាក់កណ្តាល ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីទីកន្លែងនៃការចាប់ផ្តើមចេញដំណើរតស៊ូឆ្ពោះទៅផ្តួលរំលំរបបប្រល័យ ពូជសាសន៍ ប៉ុល ពត ដើម្បីរំដោះប្រទេសជាតិ របស់**សម្តេចតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រី នៃព្រះរាជា-ណាចក្រកម្ពុជា នៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម X16ដែលមានអ្នកចូលរួមចំនួន ៦៦រូប ស្ថិតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **គីម សន្តិភាព** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍នៃយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅប្រទេសអូស្ត្រាលី និងនូវ៉ែលហ្សេឡង់ បានអញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា (២៨ មិថុនា ១៩៥១ - ២៨ មិថុនា ២០២២) និងប្រកាសបញ្ចូលសមាជិកគណបក្សថ្មីជាច្រើនរូប ប្រគល់សេចក្តីសម្រេច និងចែកលិខិតសរសើរ ប័ណ្ណសរសើរ ជូនសមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជា នៅទីក្រុងដាវីន-Darwin ប្រទេសអូស្ត្រាលី។

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ ឥណ្ណា** ប្រធានផ្នែកវប្បធម៌ និងសាសនា នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារឆមាសទី១ ឆ្នាំ២០២២ លើកទិសដៅការងារអនុវត្តបន្តរបស់ផ្នែកវប្បធម៌ និងសាសនា នៃយុវជនគណបក្សថ្នាក់កណ្តាល និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងសមាជិកសមាជិកាក្រុមជំនួយការផ្នែកវប្បធម៌និងសាសនានៃយុវជនគណបក្សថ្នាក់កណ្តាលនៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា(វិមាន៧មករា)។

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ឯកឧត្តម **តុន សារពេជ្រ** សមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តកំពត តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ម៉ៅ ធនិន** ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពត បាននាំយកអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម **ហ៊ុន ម៉ាណែត** ជូនដល់ប្រជាជនចំនួន ៤៤គ្រួសាររួមមានអង្ករ មីត្រីខ ទឹកត្រី និងថ្នាំពេទ្យ ៧មុខ ដែលមានការអញ្ជើញចូលរួមពីសមាជិកអចិន្ត្រៃយ៍យុវជនគណបក្សខេត្ត ប្រធានផែនចំណុះ និងប្រធានអនុប្រធានសមាជិក សមាជិកា ក្រុមការងារយុវជន នៅឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។

ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ថង សាវុន** សមាជិក-យុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តមណ្ឌលគីរី បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាលជាមួយសមាជិកសមាជិកាគណបក្សប្រជាជនកម្ពុជាដែលមានការអញ្ជើញចូលរួមពីឯកឧត្តម លោក លោកស្រី ប្រធានអនុប្រធានក្រុមការងារថ្នាក់ខេត្ត ចុះជួយសង្កាត់ទាំង០៤ ក្នុងក្រុង និងសមាជិក សមាជិកាគណបក្ស សរុបចំនួន ១០០រូប នៅទីស្នាក់ការគណបក្សក្រុងសែនមនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី។



ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ស៊ូ ឥទ្ធវិសិដ្ឋ** សមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងព័ត៌មាន បានដឹកនាំកិច្ចប្រជុំក្រុមអចិន្ត្រៃយ៍ដើម្បីបូកសរុបលទ្ធផលការងារនៅឆមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅការងារអនុវត្តបន្ត ជាពិសេសគឺផែនការឆ្ពោះទៅកាន់ការបោះឆ្នោតថ្នាក់ជាតិនៅឆ្នាំ២០២៣ខាងមុខ ដែលមានការអញ្ជើញចូលរួមពីសមាជិក សមាជិកា នៃក្រុមអចិន្ត្រៃយ៍ ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងព័ត៌មាន សរុបចំនួន ១៥រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ លោកជំទាវ **ភុយ សុជាតិ** សមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងសាធារណការ និងដឹកជញ្ជូន បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែមិថុនា របស់ក្រុមការងារយុវជនគណបក្សក្រសួងដែលមានការអញ្ជើញចូលរួមពីឯកឧត្តមលោកជំទាវ លោក លោកស្រី អនុប្រធាន សមាជិកអចិន្ត្រៃយ៍ នៃក្រុមការងារយុវជនគណបក្សក្រសួង សរុបចំនួន ២១រូប។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

រយៈពេល ៥ ខែ ដើមឆ្នាំ

❋ កម្ពុជានាំចូលប្រេងឥន្ធនៈមានតម្លៃសរុបជាង ៩៧១ លានដុល្លារ កើនឡើង ៥៧,៣៦% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ ដែលមានជាង ៦១៧ លានដុល្លារ។ ក្នុងនោះការនាំចូលប្រេងសាំងមានតម្លៃជាង ៣៤២ លានដុល្លារ កើន ១០៣,១១% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០២១ និងប្រេងម៉ាស៊ូត តម្លៃ ៦២៩ លានដុល្លារ កើន ៤០,២០% ។

រយៈពេល ៦ ខែ ដើមឆ្នាំ

❋ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រមូលចំណូលពន្ធ-អាករ បានចំនួន ១.៩៧០,៥១ លានដុល្លារ កើនឡើងប្រមាណជា ៤៥២,៧៤ លានដុល្លារ ស្មើនឹង ២៩,៨៧% ធៀបនឹង ចំណូលពន្ធ-អាកក្នុងរយៈពេលដូចគ្នា ឆ្នាំ ២០២១ ស្មើនឹង ៦៩,៨៩% នៃផែនការច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

❋ ទំហំពាណិជ្ជកម្មកម្ពុជា-អន្តរជាតិមានតម្លៃជាង ២៧,២៤ពាន់លានដុល្លារអាមេរិក កើនឡើង២០,២% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដែលមានជាង២២,៦៧ពាន់លានដុល្លារ។ ក្នុងនោះ កម្ពុជានាំចេញមានតម្លៃ ១១,៣៧ពាន់លានដុល្លារ កើនឡើង៣៣,៩% និងនាំចូលមកវិញមានតម្លៃជាង១៥,៨៦ពាន់លានដុល្លារ កើនឡើង១១,៩%។

❋ ទំហំពាណិជ្ជកម្មកម្ពុជា-សហរដ្ឋអាមេរិក មានទឹកប្រាក់សរុបចំនួន ៤.៨១៦ លានដុល្លារអាមេរិក ។ ក្នុងនោះកម្ពុជានាំចេញទៅអាមេរិក សម្រេចបានក្នុងទំហំទឹកប្រាក់ចំនួន ៤.៦៤៨លានដុល្លារ កើនឡើងចំនួន៥៤,០% បើធៀបរយៈពេលដូចគ្នាឆ្នាំ២០២១ មានចំនួន៣,០១៩លានដុល្លារ និងការនាំចូលពីអាមេរិកមកកម្ពុជាវិញ មានទឹកប្រាក់ចំនួន១៦៨លានដុល្លារ កើនឡើងចំនួន៨,៧% បើធៀបរយៈពេលដូចគ្នា ឆ្នាំ២០២១ មានទឹកប្រាក់១៥៤លានដុល្លារ។

❋ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា-កាណាដា មានទឹកប្រាក់សរុប ៥៨៣,០៤ លានដុល្លារ កើនឡើង ៣៥,៦% បើធៀបរយៈពេលដូចគ្នា ឆ្នាំ ២០២១ ដែលមានទឹកប្រាក់ ៤២៩,៩៧ លានដុល្លារ។ក្នុងនោះការនាំចេញទំនិញពីកម្ពុជាទៅប្រទេសកាណាដាមានទឹកប្រាក់ ៥៦៩,១៩ លានដុល្លារ កើន ៣៨,៦% ពីចំនួន ៤១០,៦៩ លានដុល្លារ និងការនាំចូលមកកម្ពុជាមានចំនួន ១៣,៨៤ លានដុល្លារ ធ្លាក់ចុះ ២៨,២% ពី ១៩,២៨ លានដុល្លារ។

❋ ការនាំចេញកង់មានបរិមាណចំនួន១.៧០១.២៨៥ស្មើនឹងទឹកប្រាក់ ៤៥៥.៨៨៥.៤៣២,៧៨ដុល្លារ និងការនាំចូលបរិមាណចំនួន ២៨៦. ៨៧២ ស្មើនឹងទឹកប្រាក់ ៨,៦៣៩,០៧៥.៦៨ដុល្លារ។

❋ ចំណូលពីការលក់សំបុត្រឱ្យភ្ញៀវទេសចរបរទេសទៅកាន់រមណីយដ្ឋានអង្គរ មានចំនួនសរុប ៥៩.៩៨៣ នាក់ កើនជាង ១.០០០% ខណៈចំណូលទទួលបានសរុប ២.៤២០.០៨១ ដុល្លារ កើនជាង ១.០០០% បើធៀបរយៈពេលដូចគ្នានៅក្នុងឆ្នាំ ២០២១។ ដោយឡែកចំណូលបានពីការលក់សំបុត្រចូលទស្សនាប្រាសាទកោះកេរវិញ បានសរុប ១៥.៩៩០ ដុល្លារ ស្មើទេសចរចំនួន ១.០៦៦ នាក់។

❋ កម្ពុជានាំចេញស្រូវ-អង្ករ ទៅកាន់ទីផ្សារអន្តរជាតិមានបរិមាណសរុបជាង ២ លានតោន ដោយប្រមូលបានប្រាក់ជាង ៦១៥ លានដុល្លារ កើនជិត ១០០ លានដុល្លារបើធៀបរយៈពេលដូចគ្នាឆ្នាំ ២០២១ ។ ក្នុងនោះការនាំចេញអង្ករមានចំនួន ៣២៧.២០០ តោនកើនឡើង ១៦,៦៧% បើធៀបទៅនឹងឆមាសទី១ ឆ្នាំ ២០២១ ដែលមានចំនួន ២៨០.៤៥០ តោន។ ចំណែកការនាំចេញស្រូវ (ទៅវៀតណាម) មានចំនួន ១.៧៣៣.១៥៧ តោន (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ១.១៤២.១៧៥ តោន) កើនឡើង ២,៣៨ %ពីចំនួន ១.៦៩២.៨១៣ តោន។

❋ កម្ពុជានាំចេញផលិតផលដំឡូងមីសរុប ២.៣០០.៩១៩,៣៩ តោន កើនឡើង ៨២,៥៥% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០២១ ដែលមានបរិមាណសរុប ១.៦១៤.១២៩,៧៦ តោន។ ក្នុងនោះការនាំចេញចំណិតដំឡូងមីក្រៀមមាន ១.៥៣៤.៥៩០ តោនកើន ២៤,២៥%, ផលិតផលដំឡូងមីស្រស់ ៧១០. ៣០០ តោន កើន ៩៧,៩៧%,ការនាំម្សៅដំឡូងមីចេញមានចំនួន ៤៨.៩៤៨ តោន កើនឡើង ២០៧,៧៨% និងកាកសំណល់ដំឡូងមីនាំចេញមានចំនួន ៧.០៨១,៣៩ តោន កើន ៦៣,៨១% ។

❋ ក្រុមហ៊ុន/សហគ្រាសនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ បាននាំចូល-នាំចេញទំនិញក្នុងតម្លៃសរុប ១.៣៧៤ លានដុល្លារកើនឡើង ៣៨,២៣% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០២១ ដែលមានចំនួន ៩៩៤ លានដុល្លារ។

I. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវស្សា ឆ្នាំ ២០២២

ក. លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន២.១១១.៥០០ ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមានចំនួន ៥.៣០៩ ហ.ត ស្មើនឹង ០,២៥% និងដោយគ្រឿងយន្តចំនួន ២.១០៦.១៩១ ហ.ត ស្មើនឹង ៩៩,៧៥% តិចជាងឆ្នាំមុនចំនួន ៣៦៩.៤៩០ ហ.ត ។

ខ. សាបបានសរុបចំនួន ៨.៦៨៩ ហ.ត តិចជាងឆ្នាំមុនចំនួន ២.៦៩៨ ហ.ត ។

គ. លទ្ធផលស្ទូង និងព្រោះសម្រេចបានចំនួន ១.៩៨៨.៧០៩ ហ.ត ស្មើនឹង ៧៥,៤៤% នៃផែនការ ២.៦១៩.៥០០ហ.ត តិចជាងឆ្នាំមុន ៣៧១.៧៨២ ហ.ត ក្នុងនោះ ស្រូវស្រាលចំនួន ៧១១.៥២៨ ហ.ត តិចជាងឆ្នាំមុន ១០៣.៤០០ ហ.ត, ស្រូវកណ្តាលចំនួន ៨៨៩.៤៩៥ហ.ត តិចជាងឆ្នាំមុន ២១១.៨៤៥ ហ.ត, ស្រូវធ្ងន់ចំនួន ៣៥៨.៨៥៥ ហ.ត តិចជាងឆ្នាំមុន ៤៣.២៧៨ ហ.ត, ស្រូវចម្ការ ចំនួន១៥.៧៣៥ តិចជាងឆ្នាំមុន ៣.៧០៩ ហ.ត និងស្រូវឡើងទឹកចំនួន ១៣.០៩៦ ហ.ត តិចជាងឆ្នាំមុន ៩.៥៥០ ហ.ត។

II. ល្បឿនការងារបង្កបង្កើនផលដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្ម រដូវស្សាឆ្នាំ ២០២២

ក. ផ្ទៃដីដំណាំសាកវប្បកម្ម(ពោតស ដំឡូងជ្វា បន្លែគ្រប់មុខ ម្ទេស និងឪឡឹក) អនុវត្តបានចំនួន ៣៥.៣៧៤ហ.ត ស្មើនឹង ៦១,០៩% នៃផែនការ ៥៧.៩០០ ហ.ត តិចជាងឆ្នាំមុន ១១.៩៦២ ហ.ត ។

ខ. ផ្ទៃដីដំណាំឧស្សាហកម្ម (ពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកដីល្ងអំពៅក្រចៅថ្នាំជក់និងឈូក)អនុវត្តបានចំនួន៧០៧.៦៩១ ហ.ត ស្មើនឹង ៩០,៩៣% នៃផែនការ ៧៧៨.៣០០ហ.ត លើសឆ្នាំមុន ៩.១៨៨ ហ.ត ៕

វិស័យថាមពលអគ្គិសនីកម្ពុជា ជាកត្តាចម្បង និងចាំបាច់មួយ សម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម

*ឯកឧត្តម **ស៊ុយ សែម** អញ្ជើញសម្ពោធជាផ្លូវការអនុស្ថានីយ និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ថ្មីនៅខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម*

ថាមពលអគ្គិសនី គឺជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាព នានា ដែលទាមទារឱ្យ មានការយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍ ដើម្បីជំរុញល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រោះអគ្គិសនីមិនត្រឹមតែជាតម្រូវការចាំបាច់ ចំពោះតែជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋគ្រប់ៗរូបប៉ុណ្ណោះទេ ប៉ុន្តែ អគ្គិសនីក៏មានសារៈសំខាន់ចំពោះវិស័យឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម កសិកម្ម និងវិស័យផ្សេងៗ ក្នុងផ្នែកសេដ្ឋកិច្ចផងដែរ។

ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានគូសបញ្ជាក់ថា ការអភិវឌ្ឍវិស័យថាមពល អគ្គិសនី គឺដើម្បីអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា ឱ្យប្រែក្លាយទៅជាប្រទេសមួយមានការផ្គត់ផ្គង់អគ្គិសនី គ្រប់គ្រាន់ មានចីរភាពអាចទុកចិត្តបាន មានគុណភាព និងមានតម្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងប្រទេស។ ឯកឧត្តម **ស៊ុយ សែម** បានមានប្រសាសន៍ថា ការអភិវឌ្ឍវិស័យថាមពលអគ្គិសនីនេះ ជាកត្តាចម្បង និងចាំបាច់មួយសម្រាប់ គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមទាំងការផ្តល់នូវសុខុមាលភាព នៃការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនេះ ក្នុងការអភិវឌ្ឍការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ជំរុញ ការសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនីធំៗអនុស្ថានីយតភ្ជាប់គ្នាជាមួយនឹងការសាងសង់ប្រភពអគ្គិសនីបន្ថែមជាបន្តបន្ទាប់ ដើម្បីផ្តល់ប្រភពអគ្គិសនីឱ្យបានគ្រប់គ្រាន់ ទាន់តាមកំណើនសេដ្ឋកិច្ច និងឱ្យទាន់តាម កំណើននៃសេចក្តីត្រូវការប្រើប្រាស់ និងជំរុញការសាងសង់ខ្សែបណ្តាញបញ្ជូនរង និងខ្សែបណ្តាញចែក ចាយអគ្គិសនីតាមបណ្តាខេត្តនានាជាបន្តបន្ទាប់ ដើម្បីធ្វើការបញ្ជូន និងចែកចាយប្រភពអគ្គិសនីដែលយើងបានអភិវឌ្ឍន៍ទៅផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់អគ្គិសនីនៅទូទាំងប្រទេសកម្ពុជា ។ ឯកឧត្តម រដ្ឋមន្ត្រីបានថ្លែងបញ្ជាក់ថា រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចដល់ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនី និង អគ្គិសនីកម្ពុជា ក្នុងការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យថាមពល និងកៀរគរថវិកាពីដៃគូអភិវឌ្ឍន៍នានាក៏ដូចជា វិស័យឯកជន សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដើម្បីធានាបានដល់ការផ្គត់ផ្គង់ អគ្គិសនី គ្រប់គ្រាន់តាមតម្រូវការ និងប្រកបដោយគុណភាព ស្ថិរភាព និរន្តរភាព ថ្លៃសមរម្យ និងកាត់បន្ថយផលប៉ះពាល់ជាអតិបរមាដល់បរិស្ថាន និងសង្គម។

ជាក់ស្តែង ការអភិវឌ្ឍវិស័យអគ្គិសនីនៅកម្ពុជាមានកំណើនឡើងជាបន្តបន្ទាប់។ ក្នុង ឆ្នាំ២០២១ កន្លងទៅ កម្ពុជាទទួលបានទុនវិនិយោគសរុបលើវិស័យអគ្គិសនី ចំនួន ១.៦៦៩ លានដុល្លារអាមេរិក ក្នុងនោះ ការវិនិយោគដោយអគ្គិសនីកម្ពុជា មានទឹកប្រាក់ ៦៤១ លានដុល្លារ អាមេរិក និងការវិនិយោគ ដោយវិស័យឯកជន មានទឹកប្រាក់ចំនួន ១.០២៨ លានដុល្លារអាមេរិក ។

តាមរបាយការណ៍របស់អាជ្ញាធរអគ្គិសនីបានឱ្យដឹងថាការវិនិយោគលើបណ្តាញមានប្រវែង ៤១.៤៨៨ គីឡូម៉ែត្រ ក្នុងនោះ ការវិនិយោគដោយអគ្គិសនីកម្ពុជាមាន ២០.១៥០ គីឡូម៉ែត្រ និងការវិនិយោគដោយឯកជន មាន ២១.៣៣៨ គីឡូម៉ែត្រ ។ លោក **យឹម វិសិដ្ឋ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា បានមានប្រសាសន៍នៅក្នុងពិធីបូកសរុបការងាររបស់អាជ្ញាធរអគ្គិសនីកាលពីថ្ងៃទី២៣ កុម្ភៈ ២០២២ នៅសណ្ឋាគារស៊ូហ្គីតែលថា អាជ្ញាធរអគ្គិសនីកម្ពុជាមានការងារសំខាន់ ២ ដែលត្រូវអនុវត្តន៍រួមមានទី១ ការអភិវឌ្ឍការផ្គត់ផ្គង់អគ្គិសនី និងទី២ ការកែលម្អការផ្តល់សេវាអគ្គិសនីឱ្យអ្នកប្រើប្រាស់។ លោកបន្តថា គោលដៅនៃការអភិវឌ្ឍការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជាប្រទាក់គ្នា ប្រមូលផ្តុំប្រភពអគ្គិសនី ដែលបានអភិវឌ្ឍ ទាំងអស់បញ្ចូលគ្នា រួចធ្វើការបែងចែក និងអភិវឌ្ឍប្រភពអគ្គិសនីបញ្ចូលក្នុងប្រព័ន្ធជាបន្តបន្ទាប់ ដើម្បីធ្វើយ៉ាងណាឱ្យកម្ពុជាមានប្រភពអគ្គិសនីកើនឡើងទាន់តាមកំណើននៃតម្រូវការ ។

លោកបន្ថែមថា ដើម្បីសម្រេចចក្ខុវិស័យនេះ ក្រសួងរ៉ែ និងថាមពលបានកំណត់ផែនការសកម្មភាព ចំនួន ៣ ដើម្បីអនុវត្ត គឺ **ទី១** ជំរុញការវិនិយោគអភិវឌ្ឍបង្កើនសមត្ថភាព ផលិតបញ្ជូន ចែកចាយ និងការតភ្ជាប់បណ្តាញឱ្យអ្នកប្រើប្រាស់អគ្គិសនី ឱ្យទាន់តាមផែនការកំណត់ ។ **ទី២**. ជំរុញការកែលម្អការផ្តល់ សេវាអគ្គិសនីឱ្យអ្នកប្រើប្រាស់ឱ្យកាន់តែខ្លាំង ធ្វើយ៉ាងណា ឱ្យការផ្គត់ផ្គង់អគ្គិសនីមានគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានតម្លៃសមរម្យ ។ **ទី៣**. ពង្រឹងយន្តការគ្រប់គ្រងការអភិវឌ្ឍ និង ការផ្តល់សេវាអគ្គិសនីឱ្យកាន់តែមានប្រសិទ្ធភាពដោយយកចិត្តទុកដាក់លើការពង្រឹងយន្តការស្តាប់ន័យន្តការវិនិយោគ យន្តការអាជីវកម្ម យន្តការបរិស្ថាន និងកិច្ចសហប្រតិបត្តិការជាមួយដៃគូក្នុងតំបន់ និង អន្តរជាតិ។

ដោយឡែក គម្រោងសាងសង់ស្ថានីយបញ្ជូន និងបង្គោលភ្លើងរ៉ែលខ្ពស់ឆ្លងសមុទ្រ នៅក្នុងខេត្តកោះកុង ប្រទេសកម្ពុជា ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២នេះ។ គម្រោងខាងលើត្រូវបាន បញ្ចប់នៅដើមខែធ្នូ ឆ្នាំ២០២១ ហើយជាគម្រោងកិច្ចសហប្រតិបត្តិការរវាង ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិជប៉ាន ស្ថានទូត

ថាមពលអគ្គិសនីដែលផលិតចេញពីទំនប់វារីអគ្គិសនី កើនឡើងយ៉ាងខ្លាំងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ

បាវាំងប្រចាំកម្ពុជា និងក្រសួងរ៉ែ និងថាមពលកម្ពុជា។ គម្រោងនេះនឹងផ្តល់ការផ្គត់ផ្គង់អគ្គិសនីដល់ខេត្តចំនួន បី រួមមាន ខេត្តកោះកុង កំពង់ចាម និងក្រចេះ ។ ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល មានប្រសាសន៍ថានេះជាគម្រោងទ្រង់ទ្រាយធំ រួមមាន ការសាងសង់បញ្ជូន និងបំប្លែងថាមពលអគ្គិសនី ២៣០kV និងការសាងសង់បង្គោលភ្លើងតង់ស្យុងខ្ពស់ចំនួន ៤ដើម ដែលឆ្លងកាត់ដែនដីនៃខេត្តនានា ក្នុងនោះបង្គោលចំនួន៣ មានកម្ពស់ ១៦៨ម៉ែត្រ ដែលជាបង្គោលអគ្គិសនីខ្ពស់បំផុតក្នុងប្រទេសកម្ពុជា។ ឯកឧត្តម បន្តថា បន្ទាប់ពីគម្រោងនេះត្រូវបានដាក់ឱ្យដំណើរការ វានឹងជួយបណ្តាញអគ្គិសនី នៃខេត្តកោះកុង ខេត្តកំពង់ចាម និងខេត្តក្រចេះ ក្នុងប្រទេសកម្ពុជា មានទំនាក់ទំនងគ្នាទៅវិញទៅមក បំពេញតម្រូវការផ្គត់ផ្គង់ថាមពល និងផ្តល់អត្ថប្រយោជន៍ ដល់ប្រជាពលរដ្ឋកម្ពុជា ។ ឯកឧត្តម បានមានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍន៍ និងពង្រឹងថាមពលជាតិ និងការបញ្ជូនថាមពល និងការប្រែក្លាយសំដៅផ្តល់ប្រភពថាមពល និងការផ្គត់ផ្គង់ ថាមពលគ្រប់គ្រាន់សម្រាប់កំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម និងតម្រូវការអ្នកប្រើប្រាស់ ។ ឯកឧត្តម បានបន្តថា ការអភិវឌ្ឍលើវិស័យថាមពលអគ្គិសនីខាងលើគឺដើម្បីអភិវឌ្ឍន៍កម្ពុជា ឲ្យប្រែក្លាយទៅជាប្រទេសមួយមានការផ្គត់ផ្គង់អគ្គិសនីគ្រប់គ្រាន់ ចីរភាពអាចទុកចិត្តបាន មានគុណភាព និងមានតម្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងប្រទេស ដែលជាកត្តាចម្បង និងចាំបាច់បំផុត សម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមព្រម ទាំងការផ្តល់នូវសុខមាលភាព នៃការរស់នៅជូនប្រជាពលរដ្ឋ។ ទោះបីវិស័យថាមពលអគ្គិសនីកម្ពុជាបានបោះជំហ៊ាន ឈានទៅរកការផ្លាស់ប្តូរមួយក្តី រយៈពេលចុងក្រោយនេះ កម្ពុជាបានខាតបង់ទៅលើតម្លៃអគ្គិសនីជាង ១០០ លានដុល្លារ ក្រោយរងផលប៉ះពាល់ពីវិបត្តិសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន ។ ទន្ទឹមនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់ ខិតខំសន្សំសំចៃ លើការប្រើប្រាស់ថាមពលអគ្គិសនី ដោយចាប់ផ្តើមចេញពីស្ថាប័នរដ្ឋ ខណៈដែលឆ្នាំនេះ អគ្គិសនីកម្ពុជាបានឈានដល់ប្រវត្តិសាស្ត្រលើកដំបូងនៃការខាតប្រមាណ ១០០លានដុល្លារ ដោយសារតែការកើនឡើងនៃតម្លៃថាមពល។ ក្នុងពិធីសំណេះសំណាលជាមួយគណៈប្រតិភូកីឡាអាស៊ានប៉ារ៉ាហ្គេមជាង១៥០នាក់កាលពីពេលថ្មីៗកន្លងមក នៅវិមានសន្តិភាព **សម្តេចតេជោ ហ៊ុន សែន** បានបញ្ជាក់ថា បើគិតពីសេដ្ឋកិច្ចទីផ្សារ តម្លៃអគ្គិសនីនៅពេលនេះ នឹងឡើងថ្លៃរហូតដល់ទៅ ២ដង។ តែរដ្ឋមិនបានដំឡើងថ្លៃ អគ្គិសនីនោះទេ ទោះបីរដ្ឋខាតបង់ថវិកាច្រើនក្តី ក៏រាជរដ្ឋាភិបាលមិនមានផែនការក្នុងការដំឡើងថ្លៃអគ្គិសនីដែរ ខណៈដែលប្រទេសមួយចំនួនបានដំឡើងថ្លៃអគ្គិសនី ម្តងជា២ដងរួចមកហើយ។ ប៉ុន្តែសម្រាប់កម្ពុជា យើងមិនទាន់បានដំឡើងថ្លៃភ្លើងទេ រោងចក្រ សហគ្រាសមួយចំនួនប្រឈមនឹងការខាតបង់ដោយសារការឡើងថ្លៃអគ្គិសនី ប៉ុន្តែរាជរដ្ឋាភិបាលត្រូវបំពេញខាត ។

សម្តេចតេជោ ហ៊ុន សែន ថ្លែងបន្តថា នៅពេលមានកូវីដ១៩ ប្រេងចុះថ្លៃ ដល់ពេលកូវីដ១៩ ចាប់ផ្តើមថមថយ សេដ្ឋកិច្ចស្តារឡើងវិញ ប្រេងក៏បានឡើងថ្លៃល្មម។ សម្តេចបានធ្វើការកត់សម្គាល់ ការឡើងថ្លៃប្រេងនេះ គឺដោយសារសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន និងការដាក់ទណ្ឌកម្មទៅលើរុស្ស៊ីពីពួកលោក ខាងលិច។ **សម្តេចតេជោ ហ៊ុន សែន** គូសបញ្ជាក់បន្ថែមថា វិបត្តិថាមពលបានកើតពេញពិភពលោក រួចស្រេចទៅហើយ។ ឆ្នាំនេះ ចេះទេវតាជួយយើងនៅត្រង់ថា ភ្លៀងច្រើនទឹកចូលពេញអាងវារីអគ្គិសនី ធ្វើឱ្យវារីអគ្គិសនីរបស់យើងដើរបាន បូកជាមួយថាមពលពន្លឺព្រះអាទិត្យ ដែលអាចឱ្យយើងអាចកាត់បន្ថយបានការខាតបង់មួយចំនួន ប៉ុន្តែប្រសិនបើវារីអគ្គិសនីរបស់យើងដើរមិនគ្រប់ ហើយត្រូវផលិតថាមពលពី ធ្យូងថ្ម ពីប្រេងឥន្ធនៈ តម្លៃអគ្គិសនីឡើងកប់ពពក។ សម្តេចតេជោ បានថ្លែងបញ្ជាក់ថា ព្រោះសង្គ្រាម វាបានបង្កការឈឺចាប់សម្រាប់រុស្ស៊ី និងអ៊ុយក្រែនរួចស្រេចទៅហើយ ។ ប៉ុន្តែការដាក់ទណ្ឌកម្មនេះ វាមិនមែនត្រូវតែរុស្ស៊ីនោះទេ ប្រទេសដែលដាក់ទណ្ឌកម្មគេនោះក៏រងទុក្ខវេទនាដូចគ្នា និងបង្កការលំបាកដល់ប្រទេសជាច្រើននៅលើពិភពលោកដោយសារវិបត្តិថាមពលដោយសារការកើនឡើងនៃតម្លៃប្រេង ហើយនៅពេលខាងមុខអាចនឹងកើតឡើងនូវវិបត្តិស្បៀងអាហារថែមទៀតក៏អាចថាបាន ៕

គម្រោងផ្គត់ផ្គង់ប្រព័ន្ធបណ្តាញអគ្គិសនីខ្នាតតូច និងស្ថានីយសាកអាគុយដើរដោយថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជា នៅខេត្តកំពត

ប្រវត្តិ ខេត្តកំពង់ចាម

កំពង់ចាម ជាខេត្តមួយរបស់ប្រទេសកម្ពុជា ស្ថិតនៅទីវាលទំនាបកណ្តាលនៃទន្លេមេគង្គ។ ខេត្តកំពង់ចាមមានព្រំប្រទល់ ខាងលិចជាប់នឹងខេត្តកំពង់ឆ្នាំង ខាងជើងជាប់នឹងខេត្តកំពង់ធំនិងខេត្តក្រចេះ ខាងកើតជាប់នឹងខេត្តត្បូងឃ្មុំ និងនៅខាងត្បូងជាប់ជាមួយខេត្តព្រៃវែង និងខេត្តកណ្តាល។ ទីរួមខេត្តកំពង់ចាមមានចម្ងាយផ្លូវប្រវែង២២៦គ.ម. ពីរាជធានីភ្នំពេញដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ ។ ផ្ទៃដីសរុបមាន ៤៥៤៩គ.ម.ការ៉េ បច្ចុប្បន្នខេត្តកំពង់ចាមត្រូវបានបំបែកចេញជាខេត្តថ្មីមួយទៀត នៅថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៣ ដែលមានឈ្មោះហៅថា ខេត្តត្បូងឃ្មុំ។ តំបន់ដែលនៅខាងលិចនៃទន្លេមេគង្គត្រូវបានកាត់ទៅក្នុងខេត្តកំពង់ចាម ឯតំបន់ដែលនៅផ្នែកខាងកើតនៃទន្លេមេគង្គត្រូវបានកាត់ទៅជាខេត្តត្បូងឃ្មុំ។

ដោយយោងតាមការស្រាវជ្រាវនិងមតិលើកឡើងជាទូទៅបានឲ្យដឹងថា ឈ្មោះ ខេត្ត «**កំពង់ចាម**» គឺមិនមានអ្វីពាក់ពន្ធ័នឹងឈ្មោះជនជាតិចាម ឬខ្មែរឥស្លាមនោះឡើយ។

តាមឯកសារប្រវត្តិសាស្ត្របានបញ្ជាក់ថា៖ ខេត្តកំពង់ចាម ត្រូវបានបង្កើតឡើងនៅថ្ងៃទី១ ខែមករាឆ្នាំ១៨៨៥ កាលនោះមន្ត្រីបារាំងម្នាក់ មានឈ្មោះថា ហ្រាង់ស្វ័រប៊ីដាន់ ជាអ្នកត្រួតត្រាលើចៅហ្វាយខេត្តខ្មែរ។ គ្រានោះខេត្តកំពង់ចាមមានស្រុកចំនួន១០ជាចំណុះដែលរួមមាន៖

១.ស្រុកកំពង់សៀម ២.ស្រុកក្រូចឆ្មា ៣.ស្រុកព្រៃឈរ ៤.ស្រុកជើងព្រៃ ៥.ស្រុកកោះសុទិន ៦.ស្រុកកងមាស ៧.ស្រុកស្រីសន្ធរ ៨.ស្រុកស្ទឹងត្រង់ ៩.ស្រុកត្បូងឃ្មុំ ១០.ស្រុកមេមត់។

បច្ចុបន្នអតីតស្រុកត្បូងឃ្មុំត្រូវបានកាត់ចេញពីខេត្តកំពង់ចាម ដោយបង្កើតចេញជាខេត្តត្បូងឃ្មុំ ។ ហើយសព្វថ្ងៃខេត្តកំពង់ចាមត្រូវបានរៀបចំបង្កើតស្រុកមួយចំនួនឡើងវិញ ដែលមានស្រុកនិងក្រុងដូចជា៖

១.ក្រុងកំពង់ចាម (ស្រុកកំពង់ចាម) ២.ស្រុកជើងព្រៃ ៣.ស្រុកស្ទឹងត្រង់ ៤.ស្រុកកោះសុទិន ៥.ស្រុកស្រីសន្ធរ ៦.ស្រុកបាធាយ ៧.ស្រុកចម្ការលើ ៨.ស្រុកព្រៃឈរ ៩.ស្រុកកងមាស ១០.ស្រុកកំពង់សៀម ។

យោងតាមឯកសារក្រុងកំពង់ចាម បានបញ្ជាក់ថា៖ ប្រវត្តិពីអតីតកាលខេត្តកំពង់ចាម គឺជាដីកោះជាប់មាត់ទន្លេ ជាកន្លែងសំចតនៃសំពៅ និងទូកតូចធំផ្សេងៗ។ តាមការអះអាងរបស់អ្នក ស្រុកធ្លាប់រស់នៅតាំងពីបុរាណ រៀងមកបានបញ្ជាក់ថា «កំពង់ចាម» បានក្លាយមក ពីពាក្យថា «កំពង់រង់ចាំ» ដោយសារទម្លាប់ពាក្យនិយាយកំពង់រង់ចាំ ក៏ក្លាយមកថាកំពង់ចាំដែលបាត់ពាក្យរង់មួយម៉ាត់នោះទៅ។ ពាក្យថា កំពង់ចាំគឺជាកន្លែងមួយដែលនៅមាត់ទឹក ហើយដែលគេតែងតែរង់ចាំទទួលចាំទូក សំពៅ ដែលឆ្លងកាត់ ដើម្បីធ្វើដំណើរឬឆ្លងទៅទីកន្លែងតំបន់ផ្សេងៗ។ ដូចនោះហើយទើបគេឲ្យឈ្មោះថាកំពង់ចាំ។ ច្រើនដំណរក្រោយមកពាក្យកំពង់ចាំនេះ ក៏បានក្លាយមកជាពាក្យថា កំពង់ចាមវិញ ដោយហេតុថានៅទីនោះមានជនជាតិផ្សេងៗមួយចំនួនមកប្រាស្រ័យទាក់ទង រកស៊ីនៅតំបន់នេះដែលមានទាំងការអានការនិយាយមិនច្បាស់លាស់ ដូច្នោះហើយពាក្យថា កំពង់ចាំក៏បានក្លាយទៅជាកំពង់ចាមៗ ជាទម្លាប់ងាយស្រួលនិយាយ ។ ចំណេរកាលបន្តបន្ទាប់មកប្រជាជនក៏បានមករស់នៅ និងរកស៊ីនៅតំបន់នេះច្រើនឡើងៗ ក៏បង្កើតបានជាមណ្ឌលពាណិជ្ជកម្មផ្លូវទឹកយ៉ាងសំខាន់នាសម័យនោះ និងបង្កើតជាភូមិស្រុកមានអាជីវកររស់នៅកកកុញ។ រីឯពាក្យថា កំពង់រង់ចាំ ក៏ក្លាយមកជាពាក្យកំពង់ចាំ បន្ទាប់មកទៀត កំពង់ចាំ ក៏ក្លាយមកហៅថា **«កំពង់ចាម»** រហូតដល់សព្វថ្ងៃ ។ ឈ្មោះ «កំពង់ចាម» នេះក៏ពុំមាន ឯកសារ ណាមួយបញ្ជាក់ថា មានពាក់ពន្ធ័ជាមួយជនជាតិភាគតិចខ្មែរឥស្លាមដែលរស់នៅតាមដងទន្លេនោះឡើយ។ អាជ្ញាធរខេត្តកំពង់ចាមក៏បានសាងសង់រូបសំណាកមួយចំនួន ដើម្បីពន្យល់បំភ្លឺក្នុងគោលដៅ រម្លឹកនៃប្រវត្តិឈ្មោះខេត្តដែលញែកចេញពីគ្នារវាង ខេត្តត្បូងឃ្មុំដោយទន្លេមេគង្គនោះ។

ខេត្តកំពង់ចាម គឺជាទឹកដីដ៏ចំណាស់មួយដែលមានស្លាកស្នាមប្រវត្តិសាស្ត្រមុនសម័យអង្គរ និងសម័យក្រោយមកទៀតដ៏ច្រើនសន្ធឹកសន្ធាប់។ ខេត្តនេះមានប្រាសាទបុរាណទួលបុរាណនិងវត្តបុរាណផ្សេងៗ នៅសេសសល់

ជាច្រើនកន្លែងលើទឹកដីនេះ។ មិនតែប៉ុណ្ណោះ ខេត្តនេះមានទាំងធនធានធម្មជាតិដូចជា ព្រៃភ្នំ ទីវាល ទន្លេបឹង និងប្រភពទឹក ផ្សេងៗដែលជាសក្តានុពលសម្រាប់វិស័យទេសចរណ៍ និងការវិនិយោគក្នុងតំបន់។ ជាមួយនោះដែរខេត្តកំពង់ចាមមានទាំងតំបន់ទេសចរណ៍សំខាន់ៗ ដូចជា៖ ប្រាសាទនគរបាលជ័យ ប្រាសាទភ្នំជើងព្រៃ ប្រាសាទភ្នំហាន់ជ័យ ប្រាសាទព្រះធាតុទឹកថ្លា ភ្នំប្រុស ភ្នំស្រី កសិទេសចរណ៍ថ្មដារ រមណីយដ្ឋានទឹកឆា និងឆ្នេរខ្សាច់កោះប៉ែនជាដើម ។

នេះជាសមិទ្ធផលដ៏វិសេសវិសាលនៅលើទឹកដីដ៏ចំណាស់មួយនេះ ។ បច្ចុប្បន្នខេត្តកំពង់ចាមបាននឹងកំពុងបោះជំហានអភិវឌ្ឍន៍យ៉ាងលឿនលើគ្រប់វិស័យគួរជាទីមោទនៈក្រៃលែង ក្រោមការអនុវត្តតាមគោលនយោបាយ ឈ្នះៗ របស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា៕

ឯកសារ

(**មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម**)

ប្រទេសជាច្រើននឹងប្រឈមមុខវិបត្តិស្បៀងអាហារ ដោយគ្មានផលិតផលកសិកម្មពីអ៊ុយក្រែន

រដូវសាបព្រោះស្រូវសាលីឆ្នាំនេះ បានកំពុងជួបភាពអាក់អន្លង់ដោយសារតែសង្គ្រាម ដូច្នេះនៅពេលរដូវច្រូតកាត់មកដល់អ៊ុយក្រែនក៏បានទទួលទិន្នផលស្រូវសាលីតិចជាងធម្មតាដែរ ។ បើតាមការវិភាគរបស់ក្រុមហ៊ុនKayrrosតាមរយៈរូបភាពផ្កាយរណបនៅឆ្នាំ២០២២នេះ ទិន្នផលស្រូវសាលីអ៊ុយក្រែននឹងធ្លាក់ចុះ៣៥%បើប្រៀបទៅនឹងឆ្នាំ២០២១។ គួររំឭកថា អ៊ុយក្រែនជាប្រទេសដែលបានផ្គត់ផ្គង់ ១០% នៃការនាំចេញស្រូវសាលី, ជាង ៥០% នៃប្រេងផ្កាឈូកវ័ត្ត និងជាមធ្យម ៥០លានតោននៃផលិតផលកសិកម្មលើពិភពលោក។ ក្នុងរដូវសាបព្រោះដាំស្រូវសាលីឆ្នាំនេះ កសិករត្រូវជួបការលំបាកជាក់ស្តែងដូចជា ត្រូវគេចគ្រាប់បែកគ្រាប់ផ្លោង ឬខ្វះប្រេងដើម្បីបញ្ជាយានយន្តព្រោះការធ្វើកសិកម្មបែបទំនើបត្រូវពឹងផ្អែកខ្លាំងទៅលើការប្រើប្រាស់ថាមពលតួយ៉ាងដូចជាការប្រើប្រាស់ប្រេងសាំងដើម្បីដំណើរការឧបករណ៍កសិកម្ម និងដើម្បីផ្តល់ថាមពលដល់ខ្សែសង្វាក់ផ្គត់ផ្គង់ជាដើម។ ដោយមិនអាចប្រកែកបានផ្ទៃដីដាំដុះក៏បានរួមតូចជាងធម្មតាផងដែរ។

ក្រុមហ៊ុន Kayrros ដែលជំនាញខាងវិភាគរូបភាពផ្កាយរណប និងដៅទីតាំងភូមិសាស្ត្រដោយប្រើវិធីសាស្ត្រគណនាទិន្នផលរុក្ខជាតិ និងធញ្ញជាតិ បានប៉ាន់ប្រមាណថា ក្នុងដំណាក់កាលនេះ អ៊ុយក្រែននឹងមានសមត្ថភាពប្រមូលផលស្រូវសាលីត្រឹមប្រមាណតែ ២១ពាន់លានតោនតែប៉ុណ្ណោះសម្រាប់រដូវច្រូតកាត់ឆ្នាំ២០២២ ពោលគឺតិចជាងឆ្នាំ២០២១ ចំនួន ១២លានតោន។ បើធៀបទៅនឹងមធ្យមភាគ៥ឆ្នាំចុងក្រោយកន្លងមកនេះ ទិន្នផលស្រូវសាលីរបស់អ៊ុយក្រែននឹងធ្លាក់ចុះ ២៣%។ បើតាមក្រុមអ្នកជំនាញដដែលព្យាករទៀតថា ដោយសារតែការប្រយុទ្ធនៅតែបន្ត និងជម្រុំខ្លាំងលើតំបន់ភាគខាងកើតអ៊ុយក្រែនដែលជាជង្រុកស្រូវសាលីរបស់ប្រទេស កសិករដែលអាចសាបព្រោះដាំស្រូវបាននៅពេលនេះ ត្រូវប្រឈមនឹងបញ្ហាដឹកជញ្ជូន និងកន្លែងស្តុកទុកនៅពេលទទួលផល។ ចំណែកការនាំចេញតាមផ្លូវថ្នល់ និងតាមផ្លូវគោក អាចជំនួសដោយការដឹកជញ្ជូនតាមផ្លូវទឹក (នាវា) បានតែមួយភាគតូចប៉ុណ្ណោះ ដោយសារប្រទេសរុស្ស៊ីបានបិទកំពង់ផែសមុទ្រសំខាន់ៗរបស់អ៊ុយក្រែននៅ Odesa និង Mykolaiv បានធ្វើឱ្យមានការថយចុះគួរឱ្យកត់សម្គាល់នៃការនាំចេញផលិតផលកសិកម្មពីអ៊ុយក្រែនដល់ ១៥%-២០% ភាគរយនៃតួលេខមុនសង្គ្រាម។ តែកំពង់ផែអ៊ុយក្រែននៅតាមសមុទ្រខ្មៅ និងសមុទ្រAzov ដែលជាច្រកផ្តោះប្តូរពាណិជ្ជកម្ម ក៏មិនអាចធានាការនាំចេញផលិតផលកសិកម្មបានដែរ។ រដ្ឋាភិបាលអ៊ុយក្រែនកំពុងតស៊ូស្វែងរកផ្លូវជំនួសដើម្បីពង្រីកការនាំចេញផលិតផលកសិកម្ម ថ្វីត្បិតនៅតែមិនអាចគ្រប់គ្រាន់ក៏ដោយប៉ុន្តែក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ នៅក្នុងខែឧសភានេះ អ៊ុយក្រែននៅតែមានឱកាសដើម្បីបង្កើនការនាំចេញ ដូច្នេះហើយមានយុទ្ធសាស្ត្រពីរដើម្បីបង្កើនការនាំចេញបន្ថែមទៀតគឺទីមួយជ័យជំនះរបស់អ៊ុយក្រែន និងការបិទច្រក និងទីពីរគឺការពង្រីកនូវវិធីផ្សេងទៀតនៃផលិតផលទីផ្សារនេះ។

រុស្ស៊ី និងអ៊ុយក្រែនជាប្រទេសនាំចេញស្រូវសាលីដ៏ចម្បងនៅលើពិភពលោក និងតំណាងឱ្យ៣០% នៃពាណិជ្ជកម្មធញ្ញជាតិពិភពលោក។ នៅពេលប្រទេសទាំងពីរនេះមានសង្គ្រាមនឹងគ្នា ប្រទេសជាច្រើនផ្សេងទៀតដែលពឹងខ្លាំងលើការនាំចូលគ្រាប់ធញ្ញជាតិពីអ៊ុយក្រែន និងរុស្ស៊ីឆ្ពើមរង្គោះរង្គើនិងធ្លាក់ក្នុងវិបត្តិអស្ថិរភាពចំណីអាហារ។ ប្រព័ន្ធផ្គត់ផ្គង់ស្បៀងអាហារពិភពលោកក៏រងផលប៉ះពាល់ទៅតាមនោះដែរ។ ហេតុដូច្នេះហើយបានជានៅថ្ងៃក្រុមប្រទេសមហាអំណាចកសិកម្ម ៥១ប្រទេសមានអាទិ៍សហភាពអឺរ៉ុប សហរដ្ឋអាមេរិក កាណាដា និងអូស្ត្រាលីបានជួបប្រជុំគ្នានៅទីក្រុងហ្សឺណែវ ពួកគេប្តេជ្ញាធ្វើការរួមគ្នាដើម្បីធានារក្សាសុវត្ថិភាពពិភពលោក ដោយបានផ្តល់ស្បៀងអាហារឱ្យបានគ្រប់គ្រាន់មិនថាអ្នកក្រខ្លាំង អ្នកងាយរងគ្រោះ ឬជនធ្វើបំលាស់ទីទេ ហើយទីផ្សារកសិកម្មនិងស្បៀងអាហារត្រូវបើកចំហជានិច្ចប្រកបដោយតម្លាភាព និងគ្មានការដាក់បម្រាមពាណិជ្ជកម្មកសិកម្ម និងកសិឧស្សាហកម្មដោយគ្មានហេតុផលឡើយ។ យោងតាមការសិក្សារបស់ WTO ទោះបីជារុស្ស៊ី និងអ៊ុយក្រែនមានទំហំតូចក្នុងទំហំសេដ្ឋកិច្ច និងពាណិជ្ជកម្មពិភពលោកក៏ដោយ ប៉ុន្តែប្រទេសទាំងពីរដើរតួយ៉ាងសំខាន់ក្នុងវិស័យផលិតកម្មមួយចំនួន និងជាអ្នកនាំចេញទំនិញសំខាន់ៗជាច្រើន។ សង្គ្រាមបានធ្វើឱ្យតម្លៃទីផ្សារពិភពលោកកើនឡើង ជាពិសេសទំនិញកសិកម្ម និងស្បៀងអាហារ ដូចជាស្រូវសាលី សណ្តែកសៀង អង្ករ ពោត និងសាច់ ជាដើម ដែលទាំងអស់នេះបានប៉ះពាល់ដល់សន្តិសុខស្បៀងនៅក្នុងប្រទេសក្រីក្រដែលពឹងផ្អែកលើការនាំចូលពីប្រទេសរុស្ស៊ី និងអ៊ុយក្រែន។ លើសពីនេះសង្គ្រាមបានបង្កើនតម្លៃផលិតផលថាមពល និងវត្ថុធាតុដើមដូចជាប្រេងនិងជី ដែលប៉ះពាល់ដោយប្រយោលដល់តម្លៃម្ហូបអាហារនៅក្នុងទីផ្សារពិភពលោក ។ ការសិក្សាបានរកឃើញថាផលិតផល ដែលប្រឈមនឹងការខ្វះខាត និងការរាំងស្ទះក្នុងផលិតកម្ម គឺផលិតផលដែលទាក់ទងនឹងប្រេងផ្កាឈូកវ័ត្ត ស្រូវសាលី ពោត និងជី ដោយសារប្រទេសរុស្ស៊ី និងអ៊ុយក្រែនមានសមាមាត្រទិន្នផលខ្ពស់ ហើយមានប្រទេសផលិតជំនួសតិចតួច។ ក្នុងនោះប្រទេសរុស្ស៊ី និងអ៊ុយក្រែន គឺជាប្រទេសដែលតំណាងឱ្យជិតមួយភាគបីនៃការផ្គត់ផ្គង់ស្រូវសាលី និងធញ្ញជាតិសំខាន់ៗលើសកលលោក ខណៈដែលអ៊ុយក្រែនក៏ជាប្រទេសនាំចេញ ផលិតផល

តទៅទំព័រទី ២៨

ពេលវេលាល្អ និងរបៀបទទួលទានទឹកដោះគោឱ្យបានត្រឹមត្រូវ ជួយឱ្យសុខភាពកាន់តែល្អប្រសើរឡើង

ទឹកដោះគោ មានជាតិប្រូតេអីនកាល់ស្យូម ជាតិដែកច្រើននិងមានលក្ខណៈល្អណាស់ សម្រាប់សុខភាពរបស់មនុស្សគ្រប់ស្រទាប់វ័យ។ តែយ៉ាងណា យើងក៏ត្រូវតែដឹងពីរបៀប ក៏ដូចជាពេលវេលាក្នុងការទទួលទានទឹកដោះគោដែរ ដើម្បីជួយឱ្យសុខភាពយើងបានល្អនិងរឹងមាំ។

១. តើទឹកដោះគោអាចផឹកបានប៉ុន្មានក្នុងមួយថ្ងៃ ?

ទឹកដោះគោ គឺល្អសម្រាប់ការអភិវឌ្ឍមនុស្ស ក្នុងសមាសភាពអាហារូបត្ថម្ភរបស់ទឹកដោះគោមានមីក្រូសារជាតិសំខាន់ៗ និងវីតាមីន ៩ ដូចជាប្រូតេអីន វីតាមីន A, D, B12, កាល់ស្យូម, ប៉ូតាស្យូម, ផូស្វ័រ, វីតាមីន B2, niaxin, ស័ង្កសី និងម៉ាញ៉េស្យូម។ សម្រាប់មនុស្សពេញវ័យ និងមនុស្សវ័យជំទង់ ការទទួលទានទឹកដោះគោ គ្មានជាតិខ្លាញ់ ឬផលិតផលធ្វើពីទឹកដោះគោជូរ ៣ ពែងក្នុងមួយថ្ងៃគឺ ២០០ មីលីក្រាម / ថ្ងៃគឺល្អសម្រាប់សុខភាព។

២.ពេលវេលាដើម្បីផឹកទឹកដោះគោសម្រាប់ការស្រូបយកជាតិកាល់ស្យូមល្អ

ផឹកទឹកដោះគោនៅពេលព្រឹក ៖ ជាពេលវេលាមួយដែលអ្នកគួរតែផឹកទឹកដោះគោនៅពេលព្រឹក។ នេះគឺជាពេលវេលាដែលរាងកាយអាចស្រូបយកសារធាតុចិញ្ចឹមទាំងអស់នៅក្នុងទឹកដោះគោ ។ អ្នកពិតជាអាចផឹកទឹកដោះគោឬបន្ថែមទឹកដោះគោទៅជាមួយនឹងធញ្ញជាតិម្សៅ គឺជាវិធីដ៏ល្អ និងមានប្រសិទ្ធភាពក្នុងការចាប់ផ្តើមថ្ងៃថ្មី ដែលនឹងផ្តល់ផលល្អដល់សុខភាពអ្នក។

ផឹកទឹកដោះគោនៅពេលរសៀល៖ ជាពេលវេលាមួយដែលមនុស្សតែងតែចង់ញ៉ាំអាហារសម្រន់ដោយសារតែអារម្មណ៍ឃ្លាន។ នៅពេលនេះជំនួសឱ្យអាហារចៀនអាហារសម្រន់ដូចជានំ ប៊ីសស្ទីន ភេសជ្ជៈផ្សេងៗ... អ្នកអាចផឹកទឹកដោះគោមួយកែវបានគីល្អ ។ នៅពេលនេះរាងកាយកំពុងខ្វះថាមពល ប៉ុន្តែមិនដល់ចំណុចនៃភាពអត់ឃ្លានខ្លាំងនឹងជួយឱ្យរាងកាយរបស់កុមារស្រូបយកសារធាតុចិញ្ចឹមដោយមិនខ្លាចរាក ឬជំងឺពោះវៀន ឡើយ។

២ម៉ោងមុនពេលចូលគេងពេលយប់៖ នេះជាពេលវេលាសមស្របដើម្បីជួយអ្នកផឹកទឹកដោះគោមានសុខភាពល្អ។ ដោយសារតែការផឹកទឹកដោះគោ នៅពេលនេះនឹងជួយមនុស្សឱ្យស្រូបយក casein ដែលជាប្រូតេអីន នៅក្នុងទឹកដោះគោ។ លើសពីនេះទៀតនៅពេលទទួលយកនៅពេលល្ងាចមាតិកាទ្រីប៉ូតាហ្វាននៅក្នុងទឹកដោះគោមានប្រសិទ្ធិភាពស្ងប់ស្ងាត់ និង sedative ជួយ ឱ្យអ្នកគេងលក់ស្រួលថែមទៀតផង។

៣. បម្រាមមួយចំនួនពេលផឹកទឹកដោះគោ

